# បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

ដោយៈនាយកដ្ឋានផលិតកម្ម និងបសុពេទ្យ

## ១. អំពីពូជ

ពូជជ្រូកមានបីប្រភេទ គឺពូជក្នុងស្រុក ពូជនាំចូល និងពូជកូនកាត់ ។

### ១.១. ពូជក្នុងស្រុក

ជាពូជជ្រូកដែលងាយចិញ្ចឹម ធន់នឹងជំងឺ និងអាកាសធាតុ មិនរើសចំណី តែការលូតលាស់របស់វាយឺត និងមានមាឌតូច ។



- ពូជជ្រូកហៃណាំ : មានដើមកំណើតនៅប្រទេសចិន ។ រូបរាងរបស់វាគឺត្រចៀកក្រាស់ មាឌតូច សម្បុរស ឬសខ្មៅ។ មានទម្ងន់ ១០០គក្រ នៅពេលដែលវាមានអាយុពី ១០-១៥ខែ ។
- ពូជជ្រូកកំពត : មានប្រភពនៅខេត្តកំពត ។ វាមានច្រមុះវែង ខ្នងអ៊ែន ពោះធំ រោមខ្លី សម្បុរខ្មៅ ។ អាយុ ៨ខែ វាមានទម្ងន់ ៦០គក្រ។
- ពូជជ្រូកដំរី : មានដើមកំណើតនៅក្នុងប្រទេសយើង ខ្នងនិងក្បាលរបស់វាធំ មុខខុប ច្រមុះត្រង់ខ្លី ខ្លួនធំហើយក្រាស់ ពោះធំ ជើងមាំ ចិញ្ចឹម ១ឆ្នាំ មានទម្ងន់ ៨០គក្រ ។
- ពូជជ្រូកកណ្តុរ : មានប្រភពមកពីប្រទេសតៃវ៉ាន់ ក្បាលវាដូចកណ្តុរ ច្រមុះស្រួច ត្រចៀកស្រួច ខ្លួនខ្លី ខ្នងអ៊ែន ពោះធំ ចិញ្ចឹម ១ឆ្នាំ មានទម្ងន់ ៦០គក្រ។

### ១.២. ពូជនាំចូល

ជាពូជជ្រូកដែលចិញ្ចឹមឆាប់បានទទួលផល មានការលូតលាស់លឿន រើសចំណី មិនសូវសម្របខ្លួនទៅ នឹងលក្ខខណ្ឌធម្មជាតិ ។ ក្នុងសៀវភៅនេះសូមលើកយកពូជជ្រូកនាំចូលមួយចំនួនដែលផ្តល់នូវទិន្នផលសាច់ និងកូនខ្ពស់ មកជម្រាបជូនដូចជា ៖

- **ពូជជ្រូកយ៉កសៀរ** : មានប្រភពដើមពីប្រទេសអង់គ្លេស ។ វាមានសម្បុរស លូតលាស់លឿន និងមានកូនច្រើន
- ពូជជ្រូកឡិនដ្រាស់: មានប្រភពដើមមកពីប្រទេសដាណឺម៉ាក ដែលមានដងខ្លួនវែងជាងប្រភេទពូជជ្រូកផ្សេងទៀតមានសម្បុរស និងផលិតកូនបានច្រើន ។



ពូជជ្រូកយ៉កសៀរ



ពូជជ្រូកឡិនដ្រាស់

- **ពូជជ្រូកឌុយរ៉ុក** : មានប្រភពដើមមកពីប្រទេសអាមេរិក ។ មានសម្បុរត្នោត និងផលិតសាច់បានល្អ ។

១.៣ ពូជកូនកាត់

ជាពូជជ្រូកដែលបានមកពីការបង្កាត់រវាងបាពូជនាំចូលជាមួយមេពូជក្នុងស្រុក។ ពូជជ្រូកកូនកាត់មានការលូតលាស់លឿន មិនរើសចំណី និងធន់ទៅនឹងអាកាសធាតុ ។



ពូជជ្រូកឌុយរ៉ុក



ពូជកូនកាត់

## ២. ការជ្រើសរើសពូជ

ក. ជ្រូកបា

មានសារសំខាន់ណាស់ដល់ផលិតកម្មជ្រូក ព្រោះជ្រូកបា ១ ក្បាល អាចយកទៅបង្កាត់ជាមួយមេជ្រូកជាច្រើនក្បាលទៀត ។ ដូច្នេះដើម្បីឲ្យបានបាល្អត្រូវ ៖

- ធ្វើការជ្រើសរើសកូនជ្រូកដែលមេ-បា មានសុខភាពល្អ និងមានប្រភពច្បាស់លាស់
- កូនដែលកើតចេញពីមេជ្រូក ជាកូនក្នុងសំបុកដែលមានកម្លាំងមាំមួន
- មេរបស់វា ជាមេដែលមានកូនច្រើន និងមានដោះមិនតិចជាង ១២ ឬ(៦គូ)
- មានសុខភាពល្អ ជើងត្រង់ល្អ រឹងមាំ ក្រចកស្មើ ធំធាត់លឿន
- ប្រដាប់បន្តពូជល្អ (ពងស្វាសទាំងគូស្មើគ្នា)
- ស្បែករលោង ស្មាទូលាយ ខ្នងត្រង់ ទ្រូងបើក
- រហ័សរហួន មិនរើសចំណី
- មិនដែលមានកើតជំងឺឆ្លងណាមួយ
- មានអាយុចាប់ពី ៤៥ថ្ងៃឡើង និងមានទម្ងន់ ចាប់ពី ៥-៧គក្រ





ខ. ជ្រូកមេសម្រាប់ទុកពូជ

ដើម្បីឲ្យផលិតកម្មកូនបានច្រើន ហើយកូនធំធាត់លូតលាស់លឿន ចាំបាច់ត្រូវជ្រើសរើសមេដែល ៖

- មិនជាន់ឈាម (ខ្សែស្រឡាយជាមួយគ្នា)

- កើតចេញពីមេដែលមានកូនច្រើន ( យ៉ាងតិច ៩ក្បាល )
- មាឧមាំ ធំជាងគេក្នុងហ្វូង មានដោះមិនតិចជាង ៦គូ
- មានសុខភាពល្អ ជើងត្រង់ល្អ រឹងមាំ ក្រចកស្មើ ធំធាត់លឿន
- ប្រដាប់បន្តពូជលូតលាស់ល្អស្បែករលោង ស្មាទូលាយ ខ្នងត្រង់ ទ្រូងបើក រហ័សរហួន មិនរើសចំណី
- មិនដែលមានកើតជំងឺឆ្លងណាមួយ
- មានអាយុចាប់ពី ៤៥ថ្ងៃឡើង និងមានទម្ងន់ចាប់ពី ៥-៧គក្រ





### គ. ជ្រូកសាច់

កូនដែលត្រូវជ្រើសរើសយកមកចិញ្ចឹមធ្វើជាជ្រូកសាច់ ដូចជា ៖

- កូនជ្រូកដែលបង្កាត់ពីរពូជបញ្ចូលគ្នា ( មេពូជផ្សេង បាពូជផ្សេងពីគ្នា )
- ប្រវត្តិច្បាស់លាស់
- មេរបស់វា ជាមេដែលមានកូនច្រើន និងមានដោះមិនតិចជាង ១២ ឬ ៦ គូរ
- មានសុខភាពល្អ ជើងត្រង់ល្អ រឹងមាំ ក្រចកស្មើ ធំធាត់លឿន
- ប្រដាប់បន្តពូជល្អ
- ស្បែករលោង ស្មាទូលាយ ខ្នងត្រង់ ទ្រូងបើក
- រហ័សរហួន មិនរើសចំណី
- មិនដែលមានកើតជំងឺឆ្លងណាមួយ
- មានអាយុចាប់ពី ៤៥ថ្ងៃឡើង និងមានទម្ងន់ចាប់ពី ៥-៧គក្រ





ពូជជ្រូកយកសាច់

# ៣. ការសាងសង់ទ្រុង

### ក. ទីតាំង និងទំហំ

ទ្រុងត្រូវសាងសង់នៅលើដីដែលមិនលិចទឹក មិននៅជាប់នឹងផ្ទះ មានខ្យល់ ពន្លឺចេញចូលគ្រប់គ្រាន់ មានទីធ្លាសមស្រប និងមានទំហំទៅតាមប្រភេទជ្រូក ។

គួរសង់ទ្រុងបណ្តោយថ្ងៃ និងគ្រប់គ្រងសីតុណ្ហភាពឲ្យបានត្រឹមត្រូវ ព្រោះសីតុណ្ហភាពជះឥទ្ធិពលខ្លាំង ដល់ការលូតលាស់របស់ជ្រូក (ទ្រុងជ្រូកសាច់ត្រូវមានសីតុណ្ហភាពពី ២៥-២៨អង្សាសេ ទ្រុងមេបំបៅកូន និងផ្តាច់ដោះ ត្រូវមានសីតុណ្ហភាពពី ៣៧-៣៨អង្សាសេ) ។

ដើម្បីធានាដល់សុវត្ថិភាពកូនជ្រូក និងដើម្បីឲ្យមេជ្រូកងាយស្រួលបំបៅកូន ព្រមទាំងកុំឲ្យមេដេកសង្កត់ ត្រូវយកចិត្តទុកដាក់បំផុតចំពោះទ្រុងមេកើតកូន ។

តារាងបង្ហាញពីទំហំទ្រុងទៅតាមប្រភេទជ្រូក នីមួយៗ

| ប្រភេទជ្រូក | ទំហំ (បណ្តោយ × ទទឹង) | កម្ពស់ទ្វារ |
|---|---|---|
| ជ្រូកក្រមុំ | ១.០០ម × ២.០០ម | ១.០០ម |
| មេបំរុង ឬមេជើម | ០.៦០-០.៦៥ម × ២.២០ម | ១.០០ម |
| ជ្រូកបាមានកន្លែងសម្រាប់បង្កាត់ | ២.២០-២.៣០ម × ៤.០០ម | ១.០០-១.៥០ម |
| មេបំបៅកូន | ៣.០០ម² | ១.០០ម |
| កូនផ្តាច់ដោះ | ២.៥០ម × ៣.០០ម (សម្រាប់កូន ១២ក្បាល) | ០.៦០ម |
| ជ្រូកសាច់ទម្ងន់ពី ៣០-៦០គក្រ | ០.៧០ម × ១.០០ម | ១.០០ម |
| ជ្រូកសាច់ទម្ងន់ ៦១គក្រ ដល់លក់ | ១.២០ម × ១.០០ម | ១.០០ម |

ទ្រុងត្រូវតែមានទ្វារមុខ និងទ្វារក្រោយ ដើម្បីងាយស្រួលចល័តពីកន្លែងមួយទៅកន្លែងមួយទៀត ។

ទ្រុងសម្រាប់មេបំបៅ ត្រូវរៀបចំជាបីផ្នែក ៖

- ទ្រុងសម្រាប់មេទំហំ ០.៦៥ម × ២.២០ម
- ទីតាំងសម្រាប់កូនដេកទំហំ ០.០២ម × ២.២០ម
- ទីតាំងសម្រាប់កូនស៊ីចំណី និងផឹកទឹកទំហំ ០.៦៥ម × ២.២០ម

### ខ. កម្រាល និងទីធ្លា

ជាទូទៅច្រើនធ្វើពីស៊ីម៉ងត៍ ដែលមានផ្ទៃរាបស្មើ និងកម្រាលរឹងមាំ។ កម្រាលគួរតែធ្វើទេរទៅផ្នែកខាងក្រោយបន្តិចដោយមានកន្លែងសម្រាប់បង្ហូរលាមក និងទឹក។





### គ. តំបូល

ទ្រុងចាំបាច់ត្រូវតែមានដំបូលត្រឹមត្រូវ ។ ដំបូលអាចធ្វើពីស្បូវ ស្លឹកត្នោត ក្បឿង ។ល។ ដំបូលដែលប្រក់ស្បូវ និងស្លឹក មិនត្រឹមតែមានតម្លៃថោកប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យទ្រុងជ្រូកត្រជាក់ល្អទៀតផង ។ ដំបូលទ្រុងជ្រូកមិនគួរប្រក់សង្ក័សីទេ ព្រោះវាស្រូបកម្ដៅខ្លាំង ហើយក៏មានតម្លៃថ្លៃដែរ ។





*ដំបូលប្រក់សង្ក័សី កំដៅប្រែប្រួលឆាប់រហ័ស ងាយនឹងកើតជំងឺផ្លូវដង្ហើម*

មុននឹងដាក់ជ្រូកចិញ្ចឹម ចាំបាច់ត្រូវលាងសំអាត និងបាចកំបោរក្នុងទ្រុង ដោយទុករយៈពេល ១សប្ដាហ៍ ទើបលាងកំបោរនោះចេញ ដើម្បីសម្លាប់មេរោគ ។









# ៤. ការផ្តល់ចំណី និងទឹក

## ក. ការផ្តល់ចំណី

ដើម្បីជួយដល់ការលូតលាស់របស់ជ្រូក ត្រូវផ្តល់ចំណីដែលមានគុណភាពល្អ និងទៅតាមតម្រូវការរបស់ជ្រូក ។ កន្ទក់ ចុងអង្ករ ពោតក្រហម សណ្តែកសៀង ដំឡូងឈើ បន្លែ កាកសំណល់ផ្ទះបាយ កាកសំណល់បាយស្រា ជាប្រភេទចំណីដែលអ្នកចិញ្ចឹមតែងយកមកប្រើប្រាស់ ។ ដើម្បីកាត់បន្ថយការចំណាយទៅលើចំណី អ្នកចិញ្ចឹមគួតែសិក្សាស្វែងយល់ពីការផលិតចំណីដោយខ្លួនឯង ដោយប្រើប្រាស់វត្ថុធាតុដើមដែលមានក្នុងស្រុក ។

### ក.១ ចំណីផ្សំស្រេច

ជាចំណីដែលត្រូវបានផលិតទៅតាមរូបមន្តត្រឹមត្រូវ និងទៅតាមប្រភេទជ្រូក ដូចជាចំណីកូនជ្រូកកំពុងបៅដោះ ចំណីកូនផ្តាច់ដោះ ចំណីមេកើតកូន ចំណីមេបំបៅកូនចំណីមេធើម ចំណីជ្រូកសាច់ ចំណីជ្រូកបា ។ ក្នុងចំណីទាំងនោះមានជាតិប្រូតេអ៊ីនគ្រប់គ្រាន់ អាចផ្តល់ឲ្យជ្រូកស៊ីដោយផ្ទាល់ដោយមិនបាច់លាយជាមួយអ្វីទាំងអស់ ។




### ក.២ មេចំណី

ជាចំណីស្ងួត ផលិតដោយមានកម្រិតប្រូតេអ៊ីន ខ្ពស់ជាងចំណីផ្សំស្រេច ។ នៅពេលដែលផ្តល់ចំណីនេះដល់ជ្រូក ចាំបាច់ត្រូវតែលាយជាមួយចំណីផ្សេងទៀត ដូចជាកន្ទក់ ពោត ចុងអង្ករ ជាដើម ទៅតាមការណែនាំរបស់ក្រុមហ៊ុនដែលផលិតចំណី ។



### ក.៣ ចំណីបែបប្រពៃណី

ជាចំណីដែលត្រូវបានផ្សំឡើងពីចុងអង្ករ កន្ទក់ បាយស្រា កាកសំណល់ផ្ទះបាយ ត្រកួន ដើមចេក ចក ផ្ទី បន្លែបង្ការផ្សេងៗទៀត ។ តែការផ្តល់ចំណីបែបប្រពៃណីនេះ ពុំមានប្រូតេអ៊ីនគ្រប់គ្រាន់សម្រាប់តម្រូវការរបស់ជ្រូកទេ ចាំបាច់ត្រូវបន្ថែមប្រូតេអ៊ីន និងវីតាមីនមួយចំនួនទៀតដូចជាម្សៅត្រី សំបកខ្យងខ្ចៅ វីតាមីនប្រេម៉ិច ជាដើម ។

អត្រានៃការលូតលាស់របស់ជ្រូកអាស្រ័យទៅលើគុណភាពចំណី និងបរិមាណនៃការស៊ីរបស់វា ។ ជ្រូក ចូលចិត្តស៊ីចំណីស្អាត ថ្មីៗ និងឈ្ងុយឆ្ងាញ់ ។ ឯបរិមាណនៃចំណីដែលផ្តល់ឲ្យជ្រូក ស្មើនឹង ៣% នៃទម្ងន់ខ្លួន របស់វា ។ យកល្អគួរផ្តល់ចំណីជ្រូកមួយថ្ងៃ ៣ដង ។




ចំណីផ្សំស្រេច និងមេចំណី ផ្តល់ឲ្យជ្រូកពូជនាំចូលអាចទទួលបានទិន្នផលខ្ពស់ ព្រោះជាចំណីដែលប្រកបដោយគុណភាព និងការគ្រប់គ្រងបានល្អ ។

សីតុណ្ហភាព និងសំណើម ក៏ជាកត្តាកាត់បន្ថយការស៊ីចំណី និងការលូតលាស់របស់ជ្រូកដែរ ។ នេះ ជាតារាងតម្រូវការចំណីទៅតាមប្រភេទជ្រូក ៖

| ប្រភេទជ្រូក | តម្រូវការចំណីប្រចាំថ្ងៃ ( គក្រ ) |
|---|---|
| មេក្រមុំ | ២.០០គក្រ |
| ជ្រូកបា | ២ - ២.៥០គក្រ |
| មេផើម | ២ - ២.៥០គក្រ |
| មេបំបៅកូន | ២ - ៤.០០គក្រ |
| មេផ្ដាច់ដោះកូន | ២.៥០ - ៣.០០គក្រ |
| កូនជ្រូកបៅដោះ | ០.៣០ - ០.៤០គក្រ |
| កូនអាយុពី ៧ថ្ងៃ-១២.០០គក្រ | ០.៥០ - ០.៨០គក្រ |
| កូនជ្រូកទម្ងន់ពី ១២-១៨គក្រ | ០.៨០ - ១.២០គក្រ |
| កូនជ្រូកទម្ងន់ពី ១៨-២៥គក្រ | ១.២០ - ១.៥០គក្រ |
| កូនជ្រូកទម្ងន់ពី ២០-៤០គក្រ | ១.៥០ - ២.០០គក្រ |
| កូនជ្រូកទម្ងន់ពី ៤០-៦០គក្រ | ២.០០ - ២.៥០គក្រ |

## ខ. សមាសធាតុសំខាន់ៗក្នុងចំណី

### ខ.១. ប្រូតេអ៊ីន

ប្រូតេអ៊ីនមានសារសំខាន់ណាស់ក្នុងការផលិតសាច់ ។ វត្ថុធាតុដើមមានបរិមាណប្រូតេអ៊ីនខុសៗគ្នា ៖

- ម្សៅត្រី មានពី ៤០-៦៥%
- សណ្ដែកសៀង មាន ៤០%
- កន្ទក់ មានពី ០៩-១២%
- ពោត មាន ១២%
- ស្រូវ មាន ០៦%
- មើមដំឡូងមី មាន ០២%




ប្រូតេអ៊ីន និងខ្លាញ់ជាសមាសធាតុសំខាន់បំផុត របស់សាច់

### ខ.២. ថាមពល

ថាមពលមានតួនាទីថែរក្សារាងកាយសត្វ តែបើមានថាមពលខ្ពស់ពេក ធ្វើឲ្យជ្រូកលូតលាស់តែខ្លាញ់ ។ វត្ថុធាតុដើមដែលផ្ដល់ថាមពលមាន ៖

- ខ្លាញ់ និងម្សៅអាមីដុង គឺជាប្រភពថាមពលដ៏សំខាន់
- សណ្ដែកសៀង និងកន្ទក់ផ្ដល់ថាមពលខ្ពស់ ព្រោះវាមានជាតិប្រេង
- អង្ករ ពោត មើមដំឡូងមីក៏ជាប្រភពផ្ដល់ថាមពល ព្រោះវាសំបូរទៅដោយជាតិអាមីដុង




*ថាមពល ជួយឲ្យជ្រូកមានកម្លាំង*

### ៣.៣. អាស៊ីដអាមីណេ

ប្រសិនបើផ្ដល់អាស៊ីដអាមីណេមិនគ្រប់គ្រាន់នឹងធ្វើឲ្យការលូតលាស់របស់ជ្រូកទាបជាងកម្រិតធម្មតា។ មានអាស៊ីដអាមីណេសំខាន់ៗ ៨មុខ តែក្នុងនោះមានអាស៊ីដអាមីណេចំនួនបួនមុខ ដែលសំខាន់សម្រាប់ការលូតលាស់គឺ ៖

- លីស៊ីន (Lysin) សំខាន់ជាងគេបំផុត
- ត្រេអូនីន (Threonin) មានតួនាទីសំខាន់ទី ២ បន្ទាប់ពីលីស៊ីន
- មេត្យូនីន (Methionin) ជាទូទៅមានគ្រប់គ្រាន់
- ទ្រីបតូហ្វាន (Tryptophan) មាននៅក្នុងអង្ករ ដូច្នេះអាចផ្ដល់ឲ្យវាគ្រប់គ្រាន់

## គ. ការផ្ដល់ទឹក

ទឹកមានតួនាទីសំខាន់ណាស់ក្នុងការបញ្ជូនសារធាតុចិញ្ចឹម និងកាកសំណល់ផ្សេងៗ នៅក្នុងខ្លួនជ្រូក ។ ពិសេសទៅទៀត ទឹកជួយផលិតទឹកសន្លាក់ និងជួយរំលាយអាហារ ។ ក្នុងខ្លួនជ្រូកមានជាតិទឹកពី ៦០-៧០% ។ មេជ្រូកដើម និងមេបំបៅកូនត្រូវការទឹកពី ២៥-៣០លីត្រ/ថ្ងៃ ។ ជ្រូកត្រូវការទឹកដើម្បីរក្សាសីតុណ្ហភាពនៅក្នុងខ្លួនឲ្យមានតុល្យភាព ។ បើសិនជ្រូកផឹកទឹកមិនបានគ្រប់គ្រាន់ បណ្ដាលឲ្យសីតុណ្ហភាពនៅក្នុងខ្លួនកើនឡើង និងអាចស្លាប់បាន ។ ការផឹកទឹកស្អាត គ្មានមេរោគនឹងជួយឲ្យជ្រូកស៊ីចំណីបានច្រើន ព្រមទាំងលូតលាស់លឿន ។ ដូច្នេះហើយអ្នកចិញ្ចឹមជ្រូកទាំងអស់ត្រូវតែរៀបចំស្នូកទឹកក្បាលបឺត និងអាងស្តុកទឹកឲ្យបានត្រឹមត្រូវ ដើម្បីធានាឲ្យជ្រូកមានទឹកផឹកគ្រប់គ្រាន់ និងផ្ដល់ទៅតាមតារាងដូចខាងក្រោម ៖

| ប្រភេទជ្រូក | តម្រូវការទឹកប្រចាំថ្ងៃ (លីត្រ) |
|---|---|
| មេក្រមុំ | ១០-១៥លីត្រ |
| ជ្រូកបា | ១៥-២០លីត្រ |
| មេដើម | ១៥-២៥លីត្រ |

| | |
|---|---|
| មេបំបៅកូន | ៣០-៤០លីត្រ |
| កូនជ្រូកបៅដោះ | ០.២-០.៤លីត្រ |
| កូនអាយុពី ៧ថ្ងៃ-១២.០០គក្រ | ១-២លីត្រ |
| កូនជ្រូកទម្ងន់ពី ១២-១៨គក្រ | ២-៣លីត្រ |
| កូនជ្រូកទម្ងន់ពី ១៨-២៥គក្រ | ៣-៤លីត្រ |
| កូនជ្រូកទម្ងន់ពី ២៥-៤៥គក្រ | ៤-៦លីត្រ |
| កូនជ្រូកទម្ងន់ពី ៤៥-១០០គក្រ | ៦-១០លីត្រ |

បើប្រើទឹកអណ្ដូងសម្រាប់ទុកឲ្យជ្រូកផឹក គួរតែដួសទុកឲ្យបាន ៤៨ម៉ោង ដើម្បីឲ្យសារធាតុផ្សេងៗ សាយភាយចេញ និងកាត់បន្ថយជាតិកំបោរក្នុងទឹក ។





**នៅមានតទៅទស្សនាវដ្ដីកសិកម្មលេខ៤៦**

# បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

**តពីលេខ៤៥**

*រៀបចំដោយ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល*

## ៥. ការបង្កាត់ពូជ

### ក. ជ្រូកបាក្មេង និងជ្រូកមេក្រមុំ

ជាជ្រូកឈ្មោលក្មេងមានអាយុប្រហែល ៨ខែ ។ ចំណែកមេជ្រូកក្រមុំ ជាជ្រូកមេក្មេងមានអាយុពី ៥-៦ខែ ដែលត្រៀមខ្លួនដើម្បីបង្កាត់ពូជជាលើកដំបូង ។ ក្នុងកំឡុងពេលនេះមិនគួរឆាប់បង្កាត់ពេកទេ ព្រោះសរីរាង្គបន្តពូជមិនទាន់លូតលាស់បានល្អ ។ ដូច្នេះគួរតែបង្កាត់ នៅពេលដែលវាមានអាយុ ៧-៨ខែ នៅពេលដែលវា រកឈ្មោលជាលើកទី ២ ឬលើកទី ៣ ។ គួរតែដាក់ មេជ្រូកក្រមុំនៅក្បែរជ្រូកបា ដើម្បីឲ្យវាឆាប់រកឈ្មោល ប៉ុន្តែមិនត្រូវដាក់ឲ្យនៅជាមួយជ្រូកបាទេ ។

ពេលដែលមេជ្រូកពេញវ័យរកឈ្មោលពេញបន្ទុកគួរឲ្យជ្រូកបាក្មេងឡើងពាក់។គួរតែជួយដល់ជ្រូកបាក្មេងនៅពេលដែលវាចាប់ផ្តើមពាក់មេជាលើកដំបូង ដូចជាការជួយបញ្ចូលលឹង្គទៅក្នុងប្រដាប់បន្តពូជជ្រូកមេ ហើយទុកឲ្យវាពាក់រហូតដល់ទទួលបានជោគជ័យ ។ ក្នុងកំឡុងពេលកំពុងបង្កាត់ មិនត្រូវឲ្យមានការរំខានពីជ្រូកបា ដទៃទៀតឡើយ ។ ត្រូវដាក់ចំណីពី ២-២.៥០





គក្រ ក្នុងជ្រូកមេជ្រូកក្រមុំមួយក្បាល និងត្រូវផ្តល់បន្លែស្រស់បន្ថែមជាមួយចំណីដល់វា ។

### ខ. មេជ្រូកផ្តាច់ដោះ

មេផ្តាច់ដោះ ជាមេជ្រូកដែលផ្តាច់ដោះ និងត្រៀមរកឈ្មោល ។ ជាធម្មតាក្រោយពេលផ្តាច់ដោះ មេជ្រូកនឹងរកឈ្មោលក្នុងកំឡុងពី ៧-១៥ថ្ងៃ ។ មេជ្រូកទើបនឹងផ្តាច់ដោះរមែងតែងតែស្គម ដោយសារវាត្រូវបំបៅកូន ដូច្នេះហើយត្រូវផ្តល់ចំណីដែលមានគុណភាព (ពី ២.៥ - ៣គក្រ/ក្បាល/ថ្ងៃ) ដើម្បីឲ្យវាមានសុខភាពល្អ និងឆាប់រកឈ្មោល ។

### គ. វដ្តនៃការរកឈ្មោល

មេជ្រូករកឈ្មោលក្នុងកំឡុងពី ៧-១៥ថ្ងៃ ក្រោយពេលផ្តាច់ដោះ និងបន្ទាប់មករៀងរាល់ ២១ថ្ងៃម្តង រហូតដល់វាធើម ។ យើងអាចដឹងបានពីសញ្ញានៃការរកឈ្មោលរបស់មេជ្រូក ដោយ ៖

- នៅមិនស្ងៀម ឡើងពាក់ជ្រូកដទៃ ឆ្លេឆ្លា
- មិនសូវស៊ីចំណី
- ប្រដាប់បន្តពូជឡើងពណ៌ផ្កាឈូកចាស់ និងមានទឹករំអិលហូរចេញ
- ពេលដែលជ្រូកបាមកជិត មេជ្រូកបង្ហាញនូវអាការៈរកឈ្មោល ។

ការចាប់ផ្តើមរកឈ្មោលរបស់ជ្រូកមេ អាស្រ័យទៅតាមពូជ ។ មេជ្រូកពូជក្នុងស្រុក រកឈ្មោលនៅអាយុ ៣-៥ខែ (ទម្ងន់ ៤៥-៥០គក្រ) ឯមេជ្រូកពូជនាំចូល រកឈ្មោលអាយុពី ៦-៧ខែ (ទម្ងន់ ៦០-៧០គក្រ) ។ ជាធម្មតាចន្លោះពីការបំបែកកូន រហូតដល់រកឈ្មោលមានរយៈពេលពី ៥-១០ថ្ងៃ ។

ក្រោយពេលផ្ដាច់ដោះ មេជ្រូកត្រូវមានដងខ្លួនសមរម្យ (មិនធាត់ពេក មិនស្គមពេក) ។ ក្នុងកំឡុងពេល បំបៅដោះកូន ត្រូវផ្ដល់ចំណីដែលមានគុណភាពល្អ គ្រប់គ្រាន់ (ពី២-៤គក្រ/ថ្ងៃ) និងត្រូវផ្ដាច់ដោះនៅពេលដែល កូនមានអាយុមិនលើសពី ២៨ថ្ងៃ ។ បន្ទាប់ពីផ្ដាច់ដោះ មិនត្រូវកម្រិតចំណីឡើយ (២.៥០-៣.០០គក្រ ក្នុងមួយថ្ងៃ) និងចាក់វីតាមីន អាដេអឺ (ADE) ដល់វា ។




Vitamin ADE



ជ្រូកមានដងខ្លួនសមរម្យ ក្រោយពេលផ្ដាច់ដោះ

**បើសិនជាជ្រូកស្គមពេក វាមិនងាយនឹងរកឈ្មោលទេ**

ម្យ៉ាងទៀតពន្លឺក៏មានសារសំខាន់ណាស់ដែរក្នុងការជួយជំរុញឲ្យមេជ្រូកឆាប់រកឈ្មោល ។ មេជ្រូកត្រូវការពន្លឺ ១៨ម៉ោង/ថ្ងៃ ក្នុងនោះយប់ ៨ម៉ោង ។





ការដាក់អំពូលភ្លើងនៅទ្រុងជ្រូកមេ

### គ.១. ការបង្កាត់ដោយធម្មជាតិ

គឺជាការបង្កាត់រវាងបា និងមេជ្រូកផ្ទាល់ ។ រយៈពេលមធ្យមនៃការរកឈ្មោលមានរយៈពេល ២១ថ្ងៃ ហើយវដ្ដនេះនឹងកើតឡើងម្ដងទៀតនៅពេលដាក់បាមិនជាប់ ។

### គ.២. ការបង្កាត់ដោយសិប្បនិម្មិត

គឺជាការបង្កាត់ដោយប្រើស្ពែមរបស់ជ្រូកបា ចាក់បញ្ចូលក្នុងស្បូនរបស់មេជ្រូក ។

# ៦. ការថែទាំមេជ្រូក និងកូន

## ក. មេផើម

ដើម្បីឲ្យកូនជ្រូកមានសុខភាពល្អ ចាំបាច់ត្រូវតែរៀបចំឲ្យបានល្អមុនពេលកើតកូន ។ មេជ្រូកនឹងកើតកូន បន្ទាប់ពីផើមរយៈពេល ១១៤ថ្ងៃ ។ ក្នុងកំឡុងពេលនេះចៀសវាងកុំឲ្យមេជ្រូកមានស្ត្រេស ធ្វើការផ្លាស់មេជ្រូក ទៅទ្រុងបង្កើតកូន មួយសប្តាហ៍មុនពេលកើតកូន ។ ត្រូវលាងសំអាតទ្រុងឲ្យបានស្អាត ដោយបាញ់ថ្នាំសម្លាប់មេរោគឲ្យបាន ២សប្តាហ៍ មុននឹងដាក់មេជ្រូកផើមចូល ។

៣ សប្តាហ៍ដំបូងបន្ទាប់ពីការបង្កាត់ ជាពេលវេលាដែលសុកមានការលូតលាស់ ។ សុកលូតលាស់ល្អ អាចធ្វើឲ្យគភ៌ទទួលបានចំណីគ្រប់គ្រាន់ ។

ត្រូវផ្តល់ចំណីដែលមានគុណភាពល្អ ដោយលាយជាមួយប្រេម៉ិច មួយស្លាបព្រាកាហ្វេ ក្នុងចំណីជារៀងរាល់ថ្ងៃ ព្រោះប្រេម៉ិចជាប្រភេទម្សៅដែលមានជាតិ រ៉ែ និងវីតាមីន ។



សុកជាអ្នកចិញ្ចឹមគភ៌

ក្នុងកំឡុងពេល ៣សប្តាហ៍ចុងក្រោយ មុននឹងកើតកូនជ្រូកមានការលូតលាស់លឿន ដូចនេះការផ្តល់ចំណីមានគុណភាព ព្រមទាំងការលាយចំណីជាមួយប្រេម៉ិច នឹងជួយឲ្យកូនដែលកើតមកថ្លោស រឹងមាំ កាត់បន្ថយអត្រាស្លាប់នៅពេលកើត និងអាចបៅទឹកដោះ (Colostrum) ដំបូងបានច្រើន ។

មុនពេលកើតត្រូវផ្តោតជាពិសេសទៅលើ ៖

- ស្គមពេក ឬធាត់ពេក
- មេកើតកូនដំបូង
- មេមានបញ្ហាជើង
- មេមានបញ្ហាគៀន
- មេឈឺ មិនស៊ីចំណី ក្តៅខ្លួន ។ល។



មេមិនស្គមពេក មិនធាត់ពេក ទ្រុងស្អាត និងស្ងាត់

ការគៀននេះអាចបង្កជាជាតិពុល ធ្វើឲ្យការកើតកូនមានការលំបាក និងអាចបង្កជាជម្ងឺ រលាកស្បូន លៀសដោះ ព្រមទាំងអត់ទឹកដោះ ដូចនេះត្រូវឲ្យជ្រូកផឹកទឹកឲ្យបានច្រើន (ច្រើនជាង ៣០លីត្រ/ថ្ងៃ) និងត្រូវផ្តល់បន្លែបៃតង ឬចំណីសំបូរជាតិសរសៃឲ្យបាន ២-៣ថ្ងៃ មុនពេលជ្រូកកើតកូន ដើម្បីការពារកុំឲ្យគៀន។បើមេជ្រូក គៀន ត្រូវឧស្សាហ៍ដេញឲ្យវាដើប



លាមកគៀន

ដើរ និងបញ្ជ្រកប្រេងប៉ារ៉ាហ្វីន (Paraffin oil)។

មុនពេលកើតកូន ១០ថ្ងៃ ប្រដាប់បន្តពូជរបស់មេជ្រូកហើមប៉ោង កន្សោមដោះរីកធំ និងឡើងរឹង ។ ពេលជិតកើតកូនមេជ្រូកហាក់ដូចជាភ័យ ប្រដាប់បន្តពូជឡើង និងកន្សោមដោះឡើងតឹង មានពណ៌ក្រហមស្រស់ ។ បើច្របាច់កន្សោមដោះថ្មមៗនឹងមានទឹកដោះចេញ បញ្ជាក់ថារយៈពេលពី ៨-១២ ម៉ោងទៀត មេជ្រូក នឹងកើតកូន ។ ដូច្នេះត្រូវរៀបចំចំបើងនៅលើកម្រាល លាងសំអាតកន្សោមដោះ និងចុងដោះ ។ មុនកើត ៣០-៩០ នាទី នឹងមានហូរឈាមព្រឿងៗចេញពីប្រដាប់បន្តពូជ និងមានអាចម៍ព្រៃ ។ ចាំបាច់ត្រូវពិនិត្យមើលកំដៅក្នុងខ្លួនមេជ្រូកឡើងឬទេ ? ពិនិត្យប្រដាប់បន្តពូជមានហូរខ្ទុះ និងមានក្លិនស្អុយដែរឬទេ ? ភ្នែករបស់វាឡើងក្រហមដែរឬទេ ? បើមានបញ្ហាទាំងអស់នេះ នោះអាចនឹងមានកូនស្លាប់ក្នុងពោះ ឬកូនពិបាកកើត ឬកើតខុសពីធម្មតា ។

## ខ. មេកើតកូន

### ខ.១. ការជួយដល់មេជ្រូក

មេទើបនឹងកើតកូនជាលើកដំបូង ច្រើនពិបាកកើតកូនជាងមេជ្រូកចាស់ ។ ពេលចាប់ផ្ដើមកើត ត្រូវតែនៅជិតវាជានិច្ច ។ ជាធម្មតាចន្លោះពេលកូនកើតពីមួយ ទៅ មួយមានរយៈពេល ១០-១៥នាទី ហើយយូរបំផុត ៣០នាទី ។ ប្រសិនបើកូនកើតមកស្រួល មេជ្រូកនឹងបង្កើតកូនរួចរាល់ពី ២-៥



ម៉ោង ។

ពេលមេកើតកូនរួចបាន ៥-៦ក្បាល មេអាចអស់កម្លាំងហើយស្បូនមិនកន្ត្រាក់ ឬកន្ត្រាក់ខ្សោយ ។ ប្រសិនបើរង់ចាំដល់ ៤០នាទីហើយកូននៅតែមិនទាន់កើតបន្ត ត្រូវចាក់អុកស៊ីតុកស៊ីន (Ocytocin) ១សេសេ តាមសាច់ដុំ តែបើចាក់ថ្នាំហើយ កូននៅតែមិនទាន់កើត ត្រូវលាងសំអាតដៃជាមួយសាប៊ូ ដើម្បីសម្លាប់មេរោគ និងលាបដៃជាមួយប្រេងឆា ឬប្រេងប៉ារ៉ាហ្វីន រួចលូកដៃតាមប្រដាប់បន្តពូជ ជួយទាញយកកូន



ជ្រូកតាមចង្វាក់ នៃការខំប្រឹងរបស់មេជ្រូក ។

### ខ.២. ការធ្លាក់សុក

ត្រូវប្រាកដថាមេជ្រូកកើតកូនអស់ និងត្រូវពិនិត្យមើលចំនួនសុក ទៅតាមចំនួនកូនជ្រូកដែលបានកើត។ជាទូទៅសុកនឹងធ្លាក់អស់ពី២-៣ម៉ោងក្រោយពេលកើតកូនចុងក្រោយ

ក្រោយពេលកើតកូនអស់ រយៈពេល ៣០នាទីត្រូវចាក់អុកស៊ីតុកស៊ីន (Ocytocin) ២សេសេ ដល់មេជ្រូកតាម



*កូនចុងក្រោយកើតមកស្រោបដោយសុក*

សាច់ដុំ ដើម្បីឲ្យសុកធ្លាក់អស់ ។

ជាទូទៅ កូនជ្រូកទើបនឹងកើតមានទឹករំអិលច្រើននៅមាត់ និងច្រមុះ ។ ដូច្នេះហើយទើបត្រូវជូតសំអាតវាជាមួយក្រណាត់ស្អាត ដើម្បីឲ្យវាងាយស្រួលដកដង្ហើម ។

ជួនកាលកូនជ្រូកកើតចុងក្រោយមានស្រោមសុកជាប់ជាមួយ ដូចនេះត្រូវយកកូនជ្រូកចេញ ។

ជួនកាលកូនកើតមកខ្សោយ ហេតុនេះហើយ ត្រូវជូត



វាឲ្យស្ងួត ដើម្បីឲ្យវាមានកម្លាំង ។

ក្រោយពេលជូតខ្លួនកូនជ្រូកស្ងួត ត្រូវចងទងផ្ចិត ដោយប្រើអំបោះជ្រលក់អាល់កុល ឬអ៊ីយ៉ូឌីន ដែលមាន ចន្លោះពីពោះកូនជ្រូកប្រមាណ ៣សង្ទីម៉ែត្រ យកកន្ត្រៃដែលបានសម្លាប់មេរោគរួចមកកាត់ទងផ្ចិត ដោយឃ្លាតពី ចំណុចចង ២សង្ទីម៉ែត្រ បន្ទាប់មកយកអ៊ីយ៉ូឌីន ឬថ្នាំក្រហមមកជូតសំអាត



ទងផ្ចិតអូសលើកម្រាល មេរោគងាយឆ្លងចូល



ការចងទងផ្ចិត



ការកាត់ទងផ្ចិត



ជ្រលក់ទងផ្ចិតក្នុងសូលុយស្យុងអ៊ីយ៉ូឌីន

កន្លែងកាត់ ។

### ខ.៣. ទឹកដោះដំបូង (Colostrum)

ត្រូវប្រាកដថា មេជ្រូកកើតកូនអស់និងត្រូវពិនិត្យមើលចំនួនសុក ទៅតាមចំនួនកូនជ្រូកដែលបានកើត ។ ជាទូទៅ សុកនឹងធ្លាក់អស់ពី ២-៣ ម៉ោងក្រោយពេលកើតកូនចុង

ក្រោយ ។ រយៈពេល ៣០នាទី ក្រោយពេលកើតកូនអស់ត្រូវចាក់អុកស៊ីតុកស៊ីន (Ocytocin) ២សេសេដល់មេជ្រូកតាមសាច់ដុំ ដើម្បីឲ្យសុកធ្លាក់អស់ ។

ក្រោយពេលកើតភ្លាម ត្រូវចាប់កូនជ្រូកឲ្យបៅទឹកដោះដំបូងឲ្យបានគ្រប់កូន ព្រោះវាសំបូរថាមពល និង អង់ទីគ័រសម្រាប់ការពារជំងឺ ។ ទឹកដោះដំបូងមានច្រើន តែក្នុងរយៈពេល ២-៣ម៉ោងប៉ុណ្ណោះ ។

ក្រោយពេលកើតភ្លាម កូនជ្រូកដែលរឹងមាំនិងរត់ទៅ



ការពិនិត្យមើលទឹកដោះដំបូង



បន្ទាប់ពីកើត កូនជ្រូកវារទៅរកបៅ



ត្រូវជួយកូនជ្រូកឲ្យរកក្បាលដោះបៅ

បៅដោះភ្លាម ។

បន្ទាប់មកត្រូវកាត់ធ្មេញស្រួចទាំង ៨ (ធ្មេញព្រៃ ៤លើ ៤ក្រោម) ដោយប្រើកន្ត្រៃកាត់ក្រចក ឬកន្ត្រៃកាត់ធ្មេញដែលបានសម្លាប់មេរោគរួច ហើយកាត់យកផ្នែកស្រួចខាងលើចេញ ២/៣ ធ្វើយ៉ាងណាកុំឲ្យមានរបួសដល់អញ្ចាញធ្មេញ ។ ការកាត់នេះត្រូវធ្វើក្រោយ ពេលកើតបាន ១ថ្ងៃ ព្រោះធ្មេញកូនជ្រូកនៅទន់ មិនបែក និងមិនមានឈាមហូរច្រើន ។ ការកាត់ធ្មេញនេះ គឺការពារកុំឲ្យកូនជ្រូកខាំគ្នា និងខាំដោះមេវានៅពេលបៅ ។ ការកាត់ធ្មេញត្រូវធ្វើមុនពេលកូនជ្រូក



ការកាត់ធ្មេញកូនជ្រូក

អាយុ ៣ថ្ងៃ ។

ក្រោយពេលកាត់ធ្មេញរួច អាចកាត់កន្ទុយបាន ដោយប្រើកាំបិត ឬឡាមដែលបានសម្លាប់មេរោគ ។ ត្រូវកាត់ ៣/៤ នៃប្រវែងកន្ទុយទាំងអស់ រួចត្រូវលាបអ៊ីយ៉ូឌីន ដើម្បីការពារការចម្លងមេរោគចូល ។ ការកាត់កន្ទុយ គឺ កាត់បន្ថយការខាំកន្ទុយ ការចម្លងមេរោគនៅពេលធំ និង ការចំណាយថាមពល



ការកាត់កន្ទុយកូនជ្រូក

ឥតប្រយោជន៍ ។

បន្ទាប់ពីកើត កូនជ្រូកត្រូវការទឹកដោះបៅភ្លាមៗ តែជួនកាលមេជ្រូកមានបញ្ហាក្តៀន ដែលជាហេតុធ្វើឲ្យ ក្បាលដោះស្ងួត មានបញ្ហារលាកស្បូន លៀសដោះ និងគ្មានទឹកដោះ ។ ដូច្នេះត្រូវព្យាបាលជាបន្ទាន់ដោយ ៖

- ចាក់អុកស៊ីតុកស៊ីន (Ocytocin) 0.៥ សេសេ តាមសរសៃវ៉ែន ៣ដង/ថ្ងៃ
- ចាក់អង់ទីប៊ីយ៉ូទិក ទ្រីមេតូព្រីម ជាមួយ ស៊ុលហ្វា (Trimetoprim + Sulfa) រយៈពេល ៥ថ្ងៃ

ជាមួយគ្នានោះដែរ បើកន្សោមដោះឡើងរឹងត្រូវប្រើដិចសាមេតាសូន (Dexamethasone) ហើយបើកំដៅមេជ្រូកឡើងដល់ ៤០អង្សាសេ ត្រូវចាក់អាណាល់ហ្សាំង ៣-៤ សេសេ ក្នុងជ្រូកទម្ងន់ ១០០គក្រ បន្ថែមទៀត ។



ចាក់អុកស៊ីតុកស៊ីន តាមសរសៃវ៉ែន

### ៤.៤. ការថែរក្សាសុខភាពកូនជ្រូក

កូនជ្រូកទើបនឹងកើតស្អាត ស្ងួត ទីធ្លាសម្រាប់ដើលេងជិតៗមេ ឬឡាំងកក់ក្តៅ ដើម្បីថែរក្សាកូនជ្រូកឲ្យមានសុខភាពល្អ ចៀសវាងជំងឺរាគ និងការពារកូនជ្រូកដែលខ្សោយឲ្យរួចផុតពីសេចក្តីស្លាប់ ។

`` សំបុកជួយផ្តល់ភាពកក់ក្តៅ និងការពារកុំឲ្យមេដេកសង្កិនកូន ។ នៅពេលយប់កូនជ្រូករងារ ជាហេតុធ្វើឲ្យវាបាត់បង់ថាមពលចុះខ្សោយ និងបៅមិនបាន ។ ដូច្នេះការរៀបចំសំបុក ការកំដៅកូនជ្រូកដោយអគ្គិសនី ឬដាក់ធ្យូងក្នុងឆ្នាំងដី ជាការផ្តល់ភាពកក់ក្តៅដល់កូនជ្រូកទើបនឹងកើត (៣៧អង្សាសេ) ។ កន្លែងដែលមានភាពសុខស្រួលសម្រាប់កូនជ្រូក គឺកម្រាល



ការផ្តល់កំដៅនៅពេលយប់ដោយអំពូលអគ្គិសនី



ការផ្តល់កំដៅដល់កូនជ្រូកបន្ទាប់ពីកើត



សំបុកស្អាតល្អ



គ្មានសំបុក កូនជ្រូករងារ ដេកកៀនទ្រុង

ស្ងួត ស្អាត មិនត្រូវខ្យល់ខ្លាំង និងមានភាពកក់ក្ដៅ ។



ទ្រុងសុវត្ថិភាពសម្រាប់បង្កើតកូន



ទ្រុងបែបនេះកូនជ្រូកងាយទទួលគ្រោះថ្នាក់ដោយមេដេកកិន





ទ្រុងមានតម្លៃថោក តែមានប្រសិទ្ធិភាពក្នុងការការពារ

ត្រូវរៀបចំទ្រុងសុវត្ថិភាពសម្រាប់កូនជ្រូកដើម្បីកុំឲ្យមេដេកកិន ។

បើគ្មានទ្រុងសម្រាប់កើតកូន ទ្រុងនោះត្រូវមានរបារឹងមាំ ហើយឃ្លាតពីជញ្ជាំង ២០សង្ទីម៉ែត្រ និងមានកម្ពស់ពីកម្រាលទ្រុង ២០សង្ទីម៉ែត្រ ដើម្បីការពារកុំឲ្យកូនជ្រូកគាបនឹងជញ្ជាំង ។

ការផ្ដល់កំដៅមិនគ្រប់គ្រាន់ បណ្ដាលឲ្យពោះកូនជ្រូកត្រជាក់ ដែលបង្កលក្ខណៈងាយស្រួលដល់ការលូតលាស់របស់បាក់តេរីអ៊ីកូលី បណ្ដាលឲ្យកូនជ្រូករាគ ។ម៉្យាងទៀតនៅពេលអាកាសធាតុត្រជាក់ ធ្វើឲ្យកូនជ្រូកបាត់បង់ថាមពល ចុះខ្សោយមិនអាចដើរទៅបៅដោះបាន ជាហេតុធ្វើឲ្យកូនជ្រូកស្លាប់ ។

ពេលមានកូនជ្រូករាគ ត្រូវប្រញាប់ព្យាបាលជាបន្ទាន់ ព្រោះវានឹងធ្វើឲ្យកូនជ្រូកខ្សោះទឹកខ្លាំង ហើយពិបាកនឹងជួយសង្គ្រោះ ។ ប្រសិនបើកូនជ្រូក ១ ឬ ២ក្បាល រាគ ត្រូវព្យាបាលកូនជ្រូកទាំងអស់ ដោយចាក់ថ្នាំ កូលីស្ទីន ដូចជា ប៊ីយ៉ូកូលីស្ទីន (Biocolistine) អំពីដិចហ្សាឡោន (Ampidexalone) 0.៥សេសេ/ក្បាល ចាក់ ១ថ្ងៃ ២ដង (ព្រឹក និងល្ងាច) រហូត



កូនជ្រូកទើបនឹងកើតរាគ ដោយសារអ៊ីកូលី (E. Coli)

ដល់ជា ។

សំខាន់ជាងនេះ បើរាគកើតលើកូនជ្រូកអាយុ ១ថ្ងៃ ត្រូវពិនិត្យមេជ្រូកផងដែរ ដូចជាសីតុណ្ហភាព កន្សោមដោះ ទឹកដោះ ... ព្រោះជួនកាលកូន ជ្រូកអាចឆ្លងមេរោគអីកូលី តាមរយៈទឹកដោះ ។ ពេលកូនរាគ ត្រូវតែព្យាបាលមេផងដែរ ដោយប្រើទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (Trimetoprim + Sulfa) ចាក់ ១ថ្ងៃម្ដង រយៈពេល ៣ថ្ងៃ ។

កូនជ្រូកត្រូវការជាតិដែក ៧-៩ មក្រ/ថ្ងៃ តែតាមរយៈទឹកដោះរបស់មេផ្ដល់ឲ្យកូនជ្រូកទទួលបានត្រឹមតែ ១-២ មក្រ/ថ្ងៃ ដូចនេះត្រូវបន្ថែមជាតិដែក ៦-៧ មក្រ/ថ្ងៃ ថែមទៀត ។ កង្វះជាតិដែកបណ្ដាលឲ្យកូនជ្រូកស្លេកស្លាំង គ្រិន និងរាគ។

ដើម្បីឲ្យកូនជ្រូកមានសុខភាពល្អ រឹងមាំ រស់បានច្រើន ត្រូវអនុវត្តដូចខាងក្រោម ៖

- អាយុ ១ថ្ងៃ ត្រូវចាក់ ឡុងអាម៉ុក (Longamox) ឬ Amox LA 0.៥សេស ដើម្បីការពារមេរោគជ្រៀតចូលតាមរយៈការកាត់ទងផ្ចិត ការកាត់ធ្មេញ និងការ



*ការចាក់ ឡុងអាម៉ុក (Longamox)*

កាត់កន្ទុយ ការពារការរលាកសន្លាក់ ព្រមទាំងការធ្លាក់ពោះវៀន (អែកនី ឬក្លូន) ។



*ការចាក់ជាតិដែក (Iron dextran)*

- អាយុ ២ថ្ងៃ ត្រូវចាក់ជាតិដែក (Iron dextran) ១សេសេ តាមសាច់ដុំក និងចាក់រំលឹកម្ដងទៀត នៅពេលកូនជ្រូកមានអាយុ ៧-១០ថ្ងៃ ។ ការចាក់ជាតិដែកនេះ ដើម្បីការពារភាពស្លេកស្លាំង (កង្វះឈាម) លូតលាស់យឺត ។
- អាយុ ៣ថ្ងៃ ត្រូវបញ្ជូក តុលត្រាសេរីល (បេកុកឬអង់ទីកុក) (Toltrazuril) ១មល តាមមាត់ ដើម្បីការពារជំងឺកុកស៊ីដ្យូស (រាគពណ៌ប្រផេះ) ដែលកើតមានលើកូនជ្រូកអាយុពី ៧-១៥ថ្ងៃ ។ ជំងឺនេះពិបាកព្យាបាលណាស់ វាមិនបណ្ដាលឲ្យកូនជ្រូក



*ការបញ្ជូកតុលត្រាសេរីល*

ស្លាប់ទេ តែវាធ្វើឲ្យកូនជ្រូកលូតលាស់យឺត នៅពេលផ្ដាច់ដោះមានសភាពស្គម និងរូបរាងមិនល្អ។

### ២.៥. ការផ្ដល់ចំណីដល់មេជ្រូក

គួរផ្ដល់ចំណីដល់មេជ្រូក ២ដង/ថ្ងៃ រួមជាមួយការផ្ដល់ទឹកឲ្យបានគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព ហើយត្រូវដាក់ឲ្យមានជាប្រចាំ ។

ចំណីសំខាន់របស់កូនជ្រូកគឺទឹកដោះ ដូចនេះបើមេផ្ដល់ទឹកដោះគ្រប់គ្រាន់ វានឹងធ្វើឲ្យកូនថ្លោស ។ ដើម្បីធានាគុណភាពទឹកដោះល្អត្រូវ ៖

- ពិនិត្យលើការផឹកទឹករបស់មេ (៣០-៤០លីត្រ/ថ្ងៃ)
- បង្កើនបរិមាណប្រូតេអ៊ីនក្នុងចំណី (សណ្ដែកសៀង ម្សៅត្រី)
- នៅថ្ងៃកើតកូនមិនត្រូវផ្ដល់ចំណីដល់មេជ្រូកទេ ប៉ុន្តែត្រូវផ្ដល់ទឹកឲ្យបានគ្រប់គ្រាន់ ។ នៅថ្ងៃទីពីរ និងថ្ងៃបន្ទាប់ ត្រូវផ្ដល់ចំណីឲ្យមេជ្រូកស៊ីច្រើនជាបណ្ដើរៗ ដោយផ្ដល់ ២-៤គក្រ/ថ្ងៃ ។

### ២.៦. ការក្រៀវកូនជ្រូក

គួរអនុវត្តលើកូនជ្រូកឈ្មោលដែលមានអាយុពី ៧-១០ថ្ងៃ ព្រោះកូនជ្រូកនៅតូច ធ្វើឲ្យរបួសឆាប់ជាសះ ស្បើយ និងកូនជ្រូកនៅមានកម្លាំងខ្លាំង ដោយសារដំណាក់កាលនេះមេជ្រូកនៅមានទឹកដោះគ្រប់គ្រាន់សម្រាប់ បំបៅកូនរបស់វា ។ បច្ចេកទេសគ្រៀវមានភាពងាយស្រួល តែក៏ត្រូវមានការប្រុងប្រយ័ត្នដែរ ដើម្បីការពារកុំឲ្យ មេរោគឆ្លងចូលក្រោយពេលគ្រៀវ រលាកស្រោមពោះវៀន និងតេតាណូស ។

មុនគ្រៀវត្រូវចាក់អាណាហ្សាំង ដើម្បីបំបាត់ការឈឺចាប់ ត្រូវលាងសំអាតស្បែកពងស្វាស និងសម្ភារៈ ដែលត្រូវប្រើ ។ ត្រូវគ្រៀវចុះក្រោមបន្តិច ដើម្បីកុំឲ្យមានឈាមដក់ជាប់កន្លែងវះ ។ ប្រើកាំបិតមុតស្រួចវះ១/៣ នៃពងស្វាស វះបញ្ឈរពាក់កណ្ដាលស្បែកពងស្វាសនីមួយៗ ។ បន្ទាប់មកច្របាច់ពងស្វាសឲ្យលៀនចេញមកក្រៅ រួចទាញវាចេញ កាត់បំពង់ពងស្វាសឲ្យខ្លីតាមដែលអាចធ្វើទៅបាន ហើយបាញ់ទឹកអ៊ីយ៉ូឌីនចូលកន្លែងវះកាត់ ។ គ្រៀវរួច ត្រូវចាក់អាម៉ុកស៊ីលីន ដើម្បីការពារការជ្រៀតចូលរបស់មេរោគ និងឲ្យកូនជ្រូកនៅកន្លែងស្ងួត ។


ស្ទាបឲ្យច្បាស់ថាវាមានពងស្វាសពីរ


កូនជ្រូកមានបញ្ហាធ្លាក់ពោះវៀន ( ពងកោប)


លាងសំអាតពងស្វាសដោយអាល់កុល ឬអ៊ីយ៉ូឌីន


ច្របាច់ពងស្វាសឲ្យជាប់


វះលើពងស្វាសត្រង់ចំណុចកណ្ដាល


ឈ្ងិចពងស្វាស



កាត់បំពង់តភ្ជាប់ពងស្វាស



សម្លាប់មេរោគជាមួយអ៊ីយ៉ូឌីន

មិនត្រូវគ្រៀវកូនជ្រូកដែលមានបញ្ហាធ្លាក់ពោះវៀន (ពងកោប) ក្នុងពងស្វាសនោះទេ ។

២.៧. បញ្ហាដែលច្រើនកើតមានលើមេជ្រូក និងកូនជ្រូក

- ប្រដាប់បន្តពូជមានទឹករំលំហូរពណ៌ស បញ្ជាក់ថាស្បូនមានជំងឺឆ្លង
- កន្សោមដោះក្តៅ និងដុំពកៗ បញ្ជាក់ថាកន្សោមដោះមានជំងឺឆ្លង (ជំងឺលាសដោះ)
- មេជ្រូកដេក មិនឲ្យកូនបៅដោះ បញ្ជាក់ថាកន្សោមដោះរបស់វាមានបញ្ហា ស្ទះទឹកដោះ ឬឈឺចាប់ ដោយសារមិនបានកាត់ធ្មេញព្រៃរបស់កូនជ្រូក
- មេជ្រូកខ្វះថាមពល/ក្តៅ បញ្ជាក់ថាមេជ្រូកមិនមានសុខភាពល្អ ដែលបណ្តាលឲ្យវាមិនថែទាំកូន
- មេជ្រូកមិនស៊ីចំណី អាចបញ្ជាក់ថាការផ្តល់ចំណីច្រើនពេក ឬមិនមានទឹកផឹក ឬមេជ្រូកមិនមានសុខភាពល្អ
- កូនជ្រូកស្គម និងរោមបះ នោះបញ្ជាក់ថាខ្វះទឹកដោះ ។ តែប្រសិនបើដុសសំអាត វាមានពណ៌ស ឬស្លេកស្លាំង កូនជ្រូកអាចបណ្តាលមកពីខ្វះជាតិដែក
- កូនជ្រូកនៅមិនស្ងៀម និងនៅជិតមេវា បញ្ជាក់ថាកូនជ្រូកមិនបានទទួលទឹកដោះគ្រប់គ្រាន់ មេវាមិនមានទឹកដោះគ្រប់គ្រាន់
- កូនជ្រូកជាច្រើនដេកគរលើគ្នា បញ្ជាក់ថាកូនជ្រូករងារពេក
- កូនជ្រូកនៅគរលើគ្នា បញ្ជាក់ថាវាត្រជាក់ ឬមិនសប្បាយរីករាយ
- ក្រម៉រដំបៅក្រៀមលើមុខ និងក្បាលជង្គង់ បញ្ជាក់ថាកូនជ្រូកខាំគ្នាពេលស៊ីចំណី ពីព្រោះពួកវា មិនបានទទួលទឹកដោះគ្រប់គ្រាន់ ។ បើកូនជ្រូកមានស្នាមរលាត់តែជង្គង់ មានន័យថាកម្រាលទ្រុងគ្រើមពេក
- ស្បែកកូនជ្រូកពេលដុះសំអាតពណ៌លឿង គឺទឹកដោះមេជ្រូកដែលកូនបៅច្រើនពេក តែបើដុសសំអាតទៅពណ៌ស ឬក្រហម អាចបណ្តាលមកពីបាក់តេរី ដូចនេះត្រូវការព្យាបាលដោយអង់ទីប៊ីយ៉ូទិក
- មេជ្រូកមិនដុះអាចម៍ ឬលាមករឹងមូល បញ្ជាក់ថាមេជ្រូកគ្លៀន ធ្វើឲ្យមេជ្រូកមិនសុខស្រួល ជាបុព្វហេតុនាំឲ្យមានបញ្ហាទឹកដោះ ។

មានតទៅលេខ ៤៧

# បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

**តពីលេខ ៤៦**

*ដោយៈ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល*

## ៧. ការថែទាំ កូនផ្តាច់ដោះ ជ្រូកជំទង់ និងជ្រូកសាច់

ការផ្តាច់ដោះគឺជាការបំបែកកូនចេញពីមេ ។ នៅពេលកូនជ្រូកមានអាយុ ៣សប្តាហ៍ មេជ្រូកមិនអាចផលិតទឹកដោះឲ្យបានគ្រប់គ្រាន់សម្រាប់កូនរបស់វាបៅទេ ជាពិសេសនៅពេលបរិមាណកូនជ្រូកមានពី ៨-៩ក្បាល ក្នុងមួយសំបុក ។ដូចនេះ ត្រូវបង្ហាត់កូនជ្រូក ឲ្យចេះស៊ីចំណីនៅពេលដែលវាមានអាយុចាប់ពី ៧-១០ថ្ងៃ ។

ត្រូវផ្តល់ចំណីដែលមានប្រូតេអ៊ីនខ្ពស់ ២២% ដោយកិនឲ្យម៉ដ្ឋ ។ យកល្អគួរផ្តាច់ដោះនៅពេលដែលកូន មានអាយុ ២៨ថ្ងៃ និងមានទម្ងន់ ៨គក្រ ។



*ដាក់ចំណីបន្ថែមដល់កូនជ្រូក ក្នុងបរិមាណតិចតួច*

### ១. ការផ្តាច់ដោះ

ចំណុចសំខាន់នៃការផ្តាច់ដោះគឺ ៖

- កូនជ្រូកមានអាយុ ៤សប្តាហ៍
- មានសុខភាពល្អ
- ផ្តាច់ដោះកូនជ្រូកទាំងអស់ក្នុងសំបុក ពេលតែមួយ
- យកមេចេញពីទ្រុងបង្កើតកូន
- ចាប់កូនជ្រូកយកទៅដាក់ក្នុងទ្រុងដែលសមស្រប
- មិនត្រូវដាក់កូនជ្រូកទាំងតូច ទាំងធំ នៅលាយឡំគ្នាឡើយ ។

#### ១.១. ការរៀបចំទ្រុងផ្តាច់ដោះ

ប្រសិនបើអាច ត្រូវធ្វើឲ្យឆ្ងាយពីគេ ដើម្បីចៀសវាងកុំឲ្យឆ្លងមេរោគ ព្រោះកូនជ្រូកលែងទទួលភាពស៊ាំពីមេហើយប្រព័ន្ធការពារជំងឺរបស់វានៅខ្សោយ មិនអាចទប់ទល់នឹងមេរោគបាន ។

ទ្រុងកូនផ្តាច់ដោះ គួរសង់ខ្ពស់ផុតពីដីប្រហែល(០.៥-១ម) កម្រាលជាបន្ទះឫស្សី ឬឈើតូចៗ ឬដែក ដើម្បីកុំឲ្យទ្រុងសើម ដោយសារលាមករបស់វាមិនជាប់នៅលើកម្រាល មានខ្យល់ចេញចូលបានល្អ និងកាត់បន្ថយ ការចម្លងមេរោគ ធ្វើឲ្យឆ្ងាយពីគេ ដើម្បីចៀសវាងកុំឆ្លងមេរោគ ព្រោះកូនជ្រូកលែងទទួលភាពស៊ាំពីមេ ហើយប្រព័ន្ធការពារជំងឺរបស់វានៅខ្សោយ មិនអាចទប់ទល់នឹងមេរោគបាន ។

ទ្រុងដែលមានកម្រាលស៊ីម៉ងត៍ ជាកន្លែងស្នាក់នៅរបស់ពពួកបាក់តេរី ។ ជាពិសេសទ្រុងគគ្រើមពេក បណ្តាលឲ្យពួកមេរោគលាក់ខ្លួនចេញពីការបោសសំអាតបាន ដូចនេះ ត្រូវធ្វើការបោសសំអាតជាប្រចាំ និងត្រូវបាញ់ថ្នាំសម្លាប់មេរោគឲ្យបានញឹកញាប់ ។

យកល្អគួរមានទ្រុងផ្តាច់ដោះពីរ ព្រោះងាយស្រួលបំបែកកូនជ្រូកទៅតាមមាឌរបស់វា ។ ពេលផ្តាច់ដោះ ដំបូងចាំបាច់ត្រូវការពារកុំឲ្យកូនជ្រូកត្រូវខ្យល់ខ្លាំង ។ ទីធ្លាទូលាយកន្លែងរស់នៅកក់ក្តៅ ចំណី និងទឹកមានគុណភាពល្អ ត្រូវមានគ្រប់ពេល នៅពេលដែលកូនជ្រូកត្រូវការ ។ ត្រូវតាមសង្កេតដោយយកចិត្តទុកដាក់ និងព្យាបាលភ្លាមៗចំពោះកូនជ្រូកណាមួយដែលមានបញ្ហា ។

#### ១.២. ក្រោយពេលផ្តាច់ដោះ

មុននឹងបំបែកទៅដាក់ទ្រុងថ្មី ត្រូវទុកកូនដែលទើបផ្តាច់ដោះឲ្យនៅក្នុងទ្រុងចាស់ ១សប្តាហ៍សិន ។ ដោយគ្មានការថែទាំពីមេ បើសិនជាប្តូរទៅនៅទ្រុងថ្មីភ្លាម អាចបណ្តាលឲ្យកូនជ្រូកត្រេសខ្លាំងឡើង ជាហេតុធ្វើឲ្យកូនជ្រូកងាយទទួលជំងឺ ។

កូនជ្រូកត្រូវរស់នៅជាមួយជ្រូកផ្សេង ឬបំបែកចេញពីគ្នាទៅតាមមាឌ ជាហេតុធ្វើឲ្យពួកវាភ័យខ្លាច និងខាំគ្នា។ ត្រូវផ្តល់កំដៅដល់ពួកវា ព្រោះវាលែងបានទទួលកំដៅពីមេទៀតហើយ ។



ទ្រុងធំ និងសើម មិនល្អសម្រាប់កូនជ្រូកទើបផ្តាច់ដោះ



ទ្រុងត្រូវតែស្អាត និងស្ងួត



បន្ទាប់ពីផ្តាច់ដោះជ្រូកខាំគ្នា



ស្លាកស្នាមក្រោយពេលខាំគ្នា



កូនជ្រូករងារ និងស្រកទម្ងន់



កូនជ្រូកមានភាពកក់ក្តៅ ក្រោមកំដៅ

### ១.៣.ការផ្ដល់ទឹក និងចំណីដល់កូនជ្រូកផ្ដាច់ដោះ

កូនជ្រូកតូចៗលូតលាស់លឿនណាស់ ប្រសិនបើការថែទាំបានល្អ ផ្ដល់ចំណី និងទឹកបានគ្រប់គ្រាន់ ។

#### ការផ្ដល់ទឹក

- ត្រូវឲ្យកូនជ្រូកផឹកទឹកបានគ្រប់គ្រាន់ ពិសេសក្បាលបឺត មិនត្រូវដាក់ខ្ពស់ពេកទេ
- ក្នុងទឹកអាចមានមេរោគជាច្រើនដូចជា អ៊ីកូលី ស្ដាហ្វីឡូកុកគូស ជាដើម ។ ដូច្នេះដើម្បីការពារ កុំឲ្យកូនជ្រូករាគ ត្រូវលាយក្ល័ររីន (Chlorine) ក្នុងទឹក ២-៣ក្រាម/១០០លីត្រ



កូនជ្រូកផឹកទឹកតាមក្បាលបឺត



ការផ្ដល់ទឹកមិនសមស្រប ខ្វះខ្នាយទឹក ទ្រុងសើម

#### ការផ្ដល់ចំណី

- ចាប់ផ្ដើមការផ្ដល់ចំណីលើកទី ១ ដល់កូនជ្រូកអាយុ ២៨ថ្ងៃ ពី ២០០-២៥០ក្រាម/ក្បាល/ថ្ងៃ
- បង្កើនរបបអាហារ ១០០ក្រាម/ក្បាល/ថ្ងៃ នៅអាទិត្យនីមួយៗបន្តបន្ទាប់
- នៅអាយុ ៨សប្ដាហ៍ ត្រូវផ្ដល់ចំណីពី ៦០០-៧០០ក្រាម/ក្បាល/ថ្ងៃ
- ក្រោយពេលផ្ដាច់ដោះកូនជ្រូកងាយនឹងទទួលមេរោគដូចជា អ៊ីកូលី (E.Coli) (បង្កឲ្យរាគ) មីកូប្លាស្មា (Myco-plasma) បង្កឲ្យក្អក ដូច្នេះក្រោយពេលផ្ដាច់ដោះភ្លាម ត្រូវលាយអង់ទីប៊ីយ៉ូទិក ក្នុងចំណីឲ្យកូនជ្រូកស៊ីរយៈពេល ១០ថ្ងៃ ដូចជា ៖
  - កូលីស្ទីន ជាមួយទីឡូស៊ីន (Colistin + Tylosin)
  - ហ្វ្ល័រហ្វេនីកុល (Florfenicol)



ការលាយអង់ទីប៊ីយ៉ូទិកក្នុងចំណីកូនជ្រូក



ព្រូនធ្វើឲ្យកូនជ្រូកលូតលាស់យឺត និងខ្សោយ

- បើសិនជាមិនបានចាក់ថ្នាំអ៊ីវែម៉ិចទីន (Ivermectine) លើមេធើមមុនពេលកើតកូន ២សប្ដាហ៍ទេ នោះនៅពេលផ្ដាច់ដោះត្រូវតែចាក់ អ៊ីវែម៉ិចទីនដល់កូនជ្រូក
  - អ៊ីវែម៉ិចទីន ១% ប្រើ ០.២៥សេសេ/ក្បាល
  - អ៊ីវែម៉ិចទីន ០.២៥% ប្រើ ១សេសេ/ក្បាល

## ២. ជ្រូកជំនង់ និងជ្រូកសាច់

សំដៅចាប់ពីផ្ដាច់ដោះរហូតដល់ពេលលក់ ។ នៅពេលដែលកូនជ្រូកមានអាយុ ១២សប្ដាហ៍ ឬនៅពេលដែលវាមានទម្ងន់ ១៨-២០គក្រ ត្រូវបំបែកយកទៅដាក់ក្នុងទ្រុងជ្រូកសាច់ ។ ការបំបែកនេះបើធ្វើនៅពេល ជ្រូកនៅក្មេងពេក ឬទម្ងន់ស្រាលពេក អាចកាត់បន្ថយសមត្ថភាព និងលទ្ធភាពនៃការលូតលាស់របស់ជ្រូក ។

ទំហំទីធ្លា និងការផ្ដល់ចំណី មានសារៈសំខាន់ណាស់ ពិសេសនៅពេលដែលពួកវាកាន់តែធំ ។ ជ្រូក ដែលខ្សោយ និងតូច មិនអាចប្រជែងស៊ីជាមួយគេបាន ធ្វើឲ្យពួកវាស៊ីមិនបានគ្រប់គ្រាន់ នាំឲ្យវាកាន់តែតូចជាងគេ ។ ក្នុងទ្រុងនីមួយៗ យ៉ាងហោចណាស់ក៏មានក្បាលបឺតទឹកពីរដែរ និងមានទឹកគ្រប់ពេល ដោយត្រួតពិនិត្យ មើលទឹកជារៀងរាល់ថ្ងៃ ។

ក្នុងទ្រុង យកល្អគួរតែដាក់សីតុណ្ហមាត្រ ដើម្បីតាមដានសីតុណ្ហភាពក្នុងទ្រុង (២៥-២៨អង្សាសេ) ។





## ៨. ការធ្វើអនាម័យ និងវិធានការការពារសុខភាពសត្វ

ដើម្បីការពារជំងឺបាន គឺការរៀបចំកសិដ្ឋានឲ្យមានអនាម័យល្អ ។ ពោលគឺត្រូវសំអាតលាមកចេញពីទ្រុង ជារៀងរាល់ថ្ងៃ ។ការបោសសំអាតក្នុងទ្រុងជារៀងរាល់ថ្ងៃ ជួយកាត់បន្ថយគ្រោះថ្នាក់នៃការផ្ទុះជំងឺ ។ រាល់ពេលសំអាត គួរប្រើជាមួយថ្នាំសម្លាប់មេរោគ ដូចជាហ្វ័រម៉ាដែន ធីអេជ ៤ អ៊ីយ៉ូដារិច បាយអូគ្លីន ។

ការសម្លាប់មេរោគ និងការធ្វើអនាម័យបានល្អ កាត់បន្ថយការីករាលដាលនៃជំងឺឆ្លងទាំងឡាយ ។ ម្យ៉ាងទៀតការដាក់ជ្រូកតាមប្រភេទ និងទម្ងន់ ក៏ជាវិធីមួយជួយកាត់បន្ថយការផ្ទុះជំងឺ និងការរីករាលដាលនៃជំងឺ ផងដែរ ។

យកល្អគួរតែបំបែកកូនជ្រូកដែលតូច ឬខ្សោយជាងគេ ចេញពីកូនជ្រូកដែលមានមាឌធំ ឬខ្លាំងជាង ដើម្បីឲ្យកូនជ្រូកដែលមានមាឌតូច បានស៊ីចំណីគ្រប់គ្រាន់ ។

### ១. សកម្មភាពទូទៅ

- សំអាត និងបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំ ហើយផ្តល់ទឹក និងចំណីដែលមានគុណភាព ឲ្យបានគ្រប់គ្រាន់
- ទ្រុងត្រូវមានខ្យល់ចេញ ចូលបានល្អ (មិនត្រជាក់ពេក និងមិនក្តៅពេក)
- កម្រាលត្រូវស្ងួត និងមានអនាម័យ
- មិនត្រូវដាក់ជ្រូកក្នុងទ្រុងចង្អៀតពេក គួរដាក់តាមទម្ងន់ ប្រភេទ និងតាមអាយុ
- លុបបំបាត់ប្រភពបង្កើតមេរោគ ដូចជាលាមក ទឹកនោម កម្រាលរបស់ជ្រូកឈឺ និងជ្រូកស្លាប់
- បំបែកជ្រូកឈឺចេញពីជ្រូកជា ។ ឯជ្រូកស្លាប់ត្រូវយកទៅកប់ក្នុងរណ្តៅជម្រៅយ៉ាងតិច ១ម៉ែត្រ
- ត្រួតពិនិត្យចរាចរសត្វចេញ និងចូលក្នុងភូមិ ។

### ២. ការការពារជំងឺដោយការដាក់ដោយឡែក

- មុននឹងដាក់បញ្ចូលជ្រូកថ្មីក្នុងហ្វូង ចាំបាច់ត្រូវបង្ខាំងទុកក្នុងទ្រុងមួយដោយឡែក រយៈពេលពី ២-៣សប្តាហ៍សិន ដោយផ្តល់ទឹក និងចំណីដល់ជ្រូកឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យប្រាកដថាជ្រូកថ្មីនោះមានជំងឺ ឬគ្មានជំងឺ ។

### ៣. ការណែនាំ

- មិនត្រូវប្រើវ៉ាក់សាំងដែលហួសថ្ងៃកំណត់ ត្រួតពិនិត្យមើលពណ៌របស់វ៉ាក់សាំង និងអានការណែនាំប្រើប្រាស់ឲ្យបានច្បាស់លាស់ ចៀសវាងការប្រើលើសកម្រិត ឬចាក់បញ្ចូលថ្នាំខុសទីតាំង អាចបណ្តាលឲ្យជ្រូកអាប់សែនៅកន្លែងចាក់ ។
- វ៉ាក់សាំងត្រូវរក្សាទុកក្នុងទូទឹកកក ក្នុងសីតុណ្ហភាព ២-៨ អង្សាសេ ។ ករណីបើកលាយហើយ គួរតែប្រើឲ្យអស់ក្នុងរយៈពេល ២-៣ម៉ោង ក្រោយពេលលាយ ហើយរក្សាទុកក្នុងធុងទឹកកក ជាប្រចាំ ។ តែបើវ៉ាក់សាំងងាប់ (វ៉ាក់សាំងមានលាយជាតិប្រេង) អាចរក្សាទុកបាន ១សប្តាហ៍។
- ត្រូវស្ងោរសឺរ៉ាំង និងម្ជុល ដើម្បីសម្លាប់មេរោគ ។
- សំបក ឬសំណល់ ក្រោយពេលប្រើរួចត្រូវកប់ឲ្យបានត្រឹមត្រូវ ចៀសវាងការចម្លងជំងឺ ។
- ត្រូវចាក់វ៉ាក់សាំងលើសត្វដែលមានសុខភាពល្អ ។

## ៩. ជំងឺដែលច្រើនកើតមានលើមេជ្រូក និងកូនជ្រូក

ដើម្បីធ្វើការព្យាបាលឲ្យមានប្រសិទ្ធិភាព សំខាន់បំផុតគឺការធ្វើរោគវិនិច្ឆ័យបានច្បាស់លាស់ បើសន្និដ្ឋាន រោគសញ្ញាមិនបានត្រឹមត្រូវ មុខជាប្រើថ្នាំខុស ព្រោះថ្នាំមានប្រសិទ្ធិភាពជាក់លាក់ផ្សេងៗគ្នា ។

រោគសញ្ញា គឺជាសញ្ញាដ៏ច្បាស់នៃជំងឺ ដែលបានលេចឡើងខុសធម្មតាលើខ្លួនសត្វ ។ ដូចនេះដើម្បីធ្វើ រោគវិនិច្ឆ័យបានច្បាស់លាស់ គួរអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម ៖

- ចូលឲ្យជិតសត្វ ពិនិត្យមើលលើដងខ្លួនទាំងមូលរបស់សត្វ (ក្បាល ត្រចៀក ច្រមុះ ការដកដង្ហើម ជើង មាត់ ... តើមានស្លាកស្នាមអ្វីដែរឬទេ ?
- សង្កេតមើលការក្រោក និងការផ្លាស់ទីរបស់សត្វ
- ត្រូវប្រើសីតុណ្ហមាត្រ សម្រាប់វាស់កំដៅសត្វ
- ពិនិត្យមើលការស៊ីចំណីរបស់សត្វ
- ពិនិត្យមើលស្បែក
- ពិនិត្យមើលភ្នែក
- ពិនិត្យមើលដុំពក
- ពិនិត្យមើលទ្វារធំ និងលាមក
- ពិនិត្យមើលផ្លូវបន្តពូជ និងទឹកនោម
- ពិនិត្យមើលកន្ទ្រាមដោះ
- ពិនិត្យមើលប្រព័ន្ធប្រសាទ

### ១. រលាកស្បែក

បណ្តាលមកពីស្តាហ្វីឡូកុកគូស ។ កើតលើកូន ជ្រូកមិនទាន់ផ្តាច់ដោះ ។

#### ១.១ រោគសញ្ញា



កូនជ្រូកមានខ្ទាញ់រងើមលើស្បែក

- ដំបូងចំណុចតូចៗពណ៌ត្នោតចាស់ ចាប់ផ្តើមចេញពីផ្នែកមុខ ឬជើង
- បន្ទាប់មកប្រែទៅជាពណ៌ត្នោត ហើយរាលដាលបន្តិចម្តងៗរហូតដល់ពេញខ្លួនទាំងមូល ។

#### ១.២. ការការពារ

- ចៀសវាងកម្រាលស្អួតពេក
- លាងសំអាតដោះមេជ្រូកជាមួយអ៊ីយ៉ូឌីន ២ដង/ថ្ងៃ

#### ១.៣. ការព្យាបាល

- ការព្យាបាលគ្មានប្រសិទ្ធិភាព
- ការចាក់អាម៉ុកស៊ីលីន អិលអេ ឡាំងកូមីស៊ីន ដើម្បីការពារជំងឺឆ្លៀតឱកាស

### ២. ជំងឺក្រញ៉ិល

#### ២.១ រោគសញ្ញា

- ផ្ទាំងក្រហមធំៗនៅលើស្បែក ប្រែទៅជាខ្មៅ
- ជ្រូកស្លាប់យ៉ាងទាន់ហន់ (ករណីស្រួចស្រាវ
- កំដៅឡើងដល់ ៤១អង្សាសេ

#### ២.២. ការការពារ

- ចាក់វ៉ាក់សាំងការពារ នៅពេលជ្រូកមាន អាយុ ៣ខែ ។



ផ្ទាំងក្រហមលើស្បែក

#### ២.៣. ការព្យាបាល

- ចាក់ប៉េនីស៊ីលីន អាម៉ុកស៊ីលីន ពី ៣-៥ថ្ងៃ

## ៣. អង្ខែ

បង្កឡើងដោយបរាសិតនៅលើស្បែក ។

### ៣.១. រោគសញ្ញា

- មានចំណុចក្រហមៗជាច្រើននៅលើស្បែកសំខាន់ នៅត្រង់ខ្នង និងពោះ
- ជ្រូកនៅមិនសុខ និងត្រដុសច្រើន
- បក់ត្រចៀកចុះឡើង
- ប៉ះពាល់ដល់កំណើនទម្ងន់ប្រចាំថ្ងៃ ។



*ផ្ទាំងក្រហមលើស្បែក*

### ៣.២. ការការពារ

ព្យាបាលជ្រូករាល់ ២-៣ខែម្តង ។

### ៣.៣. ការព្យាបាល

- ចាក់អ៊ីវ៉ូមិច ១មល/៣០គក្រ ១ថ្ងៃចាក់ ២ដង រយៈពេល ១សប្ដាហ៍ ។



*រោគសញ្ញាអង្ខែនៅត្រចៀក*



*ចាក់អ៊ីវ៉ូមិចនៅក្រោមស្បែក*

## ៤. សត្វល្អិតខាំ

### ៤.១. រោគសញ្ញា

- មានស្នាមអុចៗក្រហម និងរលាត់តិចៗ លើស្បែក
- មានការបាត់បង់ឈាម និងការលូតលាស់ តិចតួច



*ស្នាមអុចបន្ទាប់ពីមូស/រុយខាំ*

### ៤.២. ការការពារ



*រុយ/មូស ខាំ រួមជាមួយការចម្លងជំងឺបន្ទាប់បន្សំ ដូចជាស្តាហ្វីឡូកុកគូស (Staphylococcus)*

- ប្រើថ្នាំបាញ់សម្លាប់សត្វល្អិត (ទ្រិចល័រហ្វុង) លើជម្រករុយ ព្យាបាលជ្រូក
- ថ្នាំប៉ុយតុកលើខ្លួនសត្វ រាល់ ២ខែម្តង
- បើស្បែករលាត់ខ្លាំង ចាក់ថ្នាំ ដិចសាមេតាសូន
- បាញ់ថ្នាំប៉ុយតុកលើខ្លួនសត្វ រាល់ ២ខែម្តង
- បើស្បែករលាត់ខ្លាំង ចាក់ថ្នាំ ដិចសាមេតាសូន ។

## ៥. ស្បែកក្រហមដោយកំដៅថ្ងៃ

### ៥.១. រោគសញ្ញា

- ស្បែកក្រហម
- ស្បែករលាក ហើយសើម
- ជ្រូកបង្ហាញការឈឺចាប់ និងនៅមិនសុខ។

### ៥.២. ការការពារ

- ត្រូវមានម្លប់នៅក្នុងទ្រុង ។

### ៥.៣. ការព្យាបាល

- បាញ់ទឹក
- មានទឹកគ្រប់គ្រាន់សម្រាប់ជ្រូកផឹក
- ចាក់ថ្នាំប៉ារ៉ាសេតាម៉ុល ។



*ស្បែកក្រហមដោយសារកំដៅថ្ងៃ*

## ៦. ជំងឺប៉េស្ត

ជាជំងឺបង្កឡើងដោយពួកវីរុស អាចកើតឡើងលើជ្រូកគ្រប់អាយុ និងបណ្តាលឲ្យកូនជ្រូកស្លាប់ស្ទើរ ១០០% ។ ជំងឺនេះអាចកើតមានជាសណ្ឋានស្រួចស្រាវ (ជ្រូកអាចស្លាប់យ៉ាងរហ័ស) និងមិនស្រួចស្រាវ (ជ្រូកមិនស្លាប់ តែវាខ្សោយ លូតលាស់យឺត) ។

ជាទូទៅជំងឺប៉េស្តមិនស្រួចស្រាវ ច្រើនបណ្តាលមកពីការចាក់វ៉ាក់សាំងមិនមានគុណភាព វ៉ាក់សាំងមិនបានថែរក្សាក្នុងធុងទឹកកកត្រឹមត្រូវ មិនបានអនុវត្តតាមកម្មវិធី ។

### ៦.១. រោគសញ្ញា

- កំដៅឡើងពី ៤០-៤១អង្សាសេ
- លាមករាគពណ៌លឿងប្រផេះ បន្ទាប់មកគៀនពណ៌ខ្មៅមូលតូចៗ
- ដំណើរទ្រេតទ្រោត ច្រើនអង្គុយចុះ នៅមិននឹង
- ស្បែកមានស្នាមអុចៗក្រហមនៅលើដងខ្លួន
- រលាកកែវភ្នែក ដោយមានហូរទឹកភ្នែក ឬឈាមចេញពីភ្នែក ។



### ៦.២. ការព្យាបាល

ជំងឺនេះគ្មានថ្នាំព្យាបាលទេ តែអាចប្រើអង់ទីប៊ីយ៉ូទិកដូចជាអាម៉ុកស៊ីលីន អុកស៊ីតេត្រាស៊ីគ្លីន ជាដើម ហើយក៏ត្រូវប្រើថ្នាំបញ្ចុះកំដៅ និងវីតាមីនផងដែរ ដើម្បីឲ្យប្រព័ន្ធការពាររបស់ជ្រូកបានប្រសើរឡើង អាចទប់ទល់ នឹងជំងឺឱកាសនិយមដូចជា មីកូប្លាស្មា សារទឹក ស្រ្តិបតូកុកគុស ... ។



*រលាកកែវភ្នែក និងឈាមហូរចេញពីភ្នែក*

៦.៣. ការការពារ

ចាក់វ៉ាក់សាំងឲ្យកូនជ្រូកនៅអាយុ ៣ សប្ដាហ៍ ៧ សប្ដាហ៍ និង ១១សប្ដាហ៍ រួចបន្ទាប់មករាល់ ៦ខែម្ដង ។

## ៧. ជំងឺត្រចៀកខៀវ (PRRS)

ជំងឺនេះបង្កឡើងដោយវីរុស ដែលអាចកើតលើជ្រូកគ្រប់អាយុ ជាពិសេសបង្កលើមេជ្រូក និងជ្រូកបា ។ ចំពោះមេ ដើមអាចរលូតកូន ឯជ្រូកបាអសមត្ថភាព ។

៧.១. រោគសញ្ញាលើមេជ្រូក

- ត្រចៀកមានពណ៌ខៀវ
- មិនសូវស៊ីចំណី ១ ទៅ ២អាទិត្យ
- រលូតកូន។



៧.២. រោគសញ្ញាលើកូនជ្រូក

- រោគសញ្ញាមានការប្រែប្រួល
- ក្អកតិចៗ
- ពិបាកដកដង្ហើម
- ស្គម មានរោមច្រើន
- ខ្សោយ ធំមិនស្មើគ្នា ងាយទទួលជំងឺ ផ្សេងទៀត



ដូចជា សាល់ម៉ូណែលឡា (រាគខៀវ) និងមីកូប្លាស្មា (ក្អកខ្លាំង)

- ស្បែកក្រហម រោមបាស់
- មិនស៊ីចំណី និងអស់កម្លាំង
- លូតលាស់យឺត សភាពដងខ្លួនមិនល្អ
- រលាកស្រោមសួត ហើមកូនកណ្ដុរ ។

៧.៣.ការព្យាបាល

- គ្មានការព្យាបាលទេ
- តែអាចប្រើអង់ទីប៊ីយ៉ូទិក អង់រ៉ូហ្លុកសាក់ស៊ីន ដើម្បីប្រឆាំងនឹងបាក់តេរី សាល់ម៉ូណែលឡា ប៉ាស្ទ័រ៉ែលឡា និងមីកូប្លាស្មា
- ត្រូវចាំថាមូលគឺជាអ្នកចម្លងវីរុស ។

៧.៤.ការការពារ

- លាយម្សៅហ្វ័រហ្វេនីកុល ក្នុងចំណីឲ្យកូនជ្រូក ២ សប្ដាហ៍ (មុនផ្ដាច់ដោះ ១សប្ដាហ៍ និងក្រោយផ្ដាច់ដោះ ១សប្ដាហ៍)

## ៨. ជំងឺក្អក

បណ្ដាលមកពីមេរោគមីកូប្លាស្មា (Mycoplasma) ដែលកើតឡើងលើកូនជ្រូកទើបផ្ដាច់ដោះ ។ មេរោគ នេះបង្កជាបញ្ហាដល់សួត ហើយកូនជ្រូកនឹងក្អកនៅពេលវាមានអាយុពី ១០-១២សប្ដាហ៍ ។

៨.១. ការព្យាបាល

- ចាក់អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ហ្វ័រហ្វេនីកុល (Florfenicol) ឬអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine)
- ប្រើរយៈពេល៥ថ្ងៃ ដោយថ្ងៃទី១ ចាក់កម្រិតទ្វេដង

៨.២. ការការពារ

- នៅពេលឃើញជ្រូកទម្ងន់ ២០-៤០គក្រ មានបញ្ហាក្អក ចាំបាច់ត្រូវលាយអង់ទីប៊ីយ៉ូទិកក្នុងចំណី
- អង់ទីប៊ីយ៉ូទិកដូចជាហ្វ័រហ្វេនីកុល (Florfenicol) ឬ ទីឡូស៊ីន (Tylosin) ឬអុកស៊ីតេត្រាស៊ីគ្លីន (Oxy-tetracycline) លាយក្នុងចំណីឲ្យកូនជ្រូកផ្ដាច់ដោះស៊ីរយៈពេល ១០ថ្ងៃ ។

សូមរង់ចាំអានវគ្គបញ្ចប់នៅលេខ៤៨

# បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

**តពីលេខ ៤៧**

*ដោយៈ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល*

## ៩. ជំងឺផ្តាសាយ

ជំងឺនេះមានសភាពធ្ងន់ ពេលថ្ងៃជ្រូកមានសភាពធម្មតា លុះដល់ព្រឹកឡើងជ្រូក ៩០%ឈឺ ។ ជ្រូក ចាប់ផ្តើមក្អក ពិបាកដកដង្ហើម សីតុណ្ហភាពឡើងលើសពី ៤០អង្សាសេ ។ ប៉ុន្តែជ្រូកនឹងជាសះស្បើយវិញក្នុងរយៈពេល ៥ថ្ងៃក្រោយ ។

ជំងឺនេះគ្មានថ្នាំព្យាបាលទេ ព្រោះវាបង្កឡើងដោយវីរុស តែអាចព្យាបាលដោយប្រើអុកស៊ីតេត្រាស៊ីគ្លីន រយៈពេល ៣ថ្ងៃ ដើម្បីទប់ស្កាត់ជំងឺឆ្លៀតឱកាស ដូចជាជំងឺសារទឹក មីកូប្លាស្មា ... ។

## ១០. ជំងឺរលាកសួត

ច្រើនកើតនៅពេលផ្តាច់ដោះ និងជ្រូកសាច់ ។ ជំងឺនេះបណ្តាលមកពីអាកាសធាតុត្រជាក់ ទ្រុងសើម និងគ្មានអនាម័យ ។

### ១០.១. រោគសញ្ញា

- ដកដង្ហើមញាប់ និងក្អកមួយៗ
- កំដៅលើសពី ៤០អង្សាសេ
- ភ្នែកក្រហម
- ចេញពណ៌ខៀវនៅលើស្បែក ។



*កូនជ្រូកពិបាកដកដង្ហើមធ្ងន់ធ្ងរ*

### ១០.២. មូលហេតុ

- ជំងឺសារទឹក : ៩០% នៃជ្រូកដែលកើតមីកូប្លាស្មា នឹងកើតជំងឺសារទឹក
- ជំងឺផ្សេងៗទៀត : ១០% គឺសាល់ម៉ូណែលឡូស (ស្រួចស្រាវ)
- និងវីរុស : អូហ្សេស្គី ផ្តាសាយជ្រូក និងជំងឺត្រចៀកខៀវ

### ១០.៣. ការព្យាបាល

- អង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពប្រឆាំងនឹងពួកមីកូប្លាស្មាមាន ហ្វ្លរហ្វេនីកុល (Florfenicol) អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) ដោយប្រើកម្រិតទ្វេដង នៅថ្ងៃទី ១ ។

## ១១. ជំងឺរលាកទីណូបាក់ស៊ីលូស (Actinobacillus)

ជំងឺនេះបង្កដោយមេរោគអាក់ទីណូបាក់ស៊ីលូស (Actinobacillus) ។

### ១១.១. រោគសញ្ញា

- ឈាមហូរមានពពុះចេញពីច្រមុះ
- កើតលើជ្រូកដែលមានអាយុពី ៨-១៦ សប្តាហ៍
- រយៈពេលសម្ងំរបស់មេរោគ ១២ម៉ោង
- ក្អកម្តងពី ១-៣ដង (ក្អកមានរយៈពេលខ្លី)
- ពិបាកដកដង្ហើម ជ្រូកចុះខ្សោយកម្លាំង
- ត្រចៀកពណ៌ខៀវ
- សីតុណ្ហភាពលើស ៤០អង្សាសេ ជ្រូកអាចស្លាប់ភ្លាមៗ ហើយអត្រាស្លាប់ខ្ពស់ ។

### ១១.២. ការព្យាបាល

- អាម៉ុកស៊ីលីន (Amoxicillin)



*ឈាមហូរមានពពុះចេញពីច្រមុះ*



ជ្រូកឈឺដោយជំងឺអាក់ទីណូបាក់ស៊ីលូស

- អង់រ៉ូហ្លុកសាក់ស៊ីន ( Enrofloxacine )
- សែហ្វទីយ៉ូហ្វៀរ ( Ceftiofur )

ដោយចាក់កម្រិតទ្វេដងនៅថ្ងៃទី១ចាក់សាច់ដុំ រយៈពេល ៣-៥ថ្ងៃជាប់គ្នា



សួតកើតជំងឺមីកូប្លាស្មា



សួតកើតជំងឺសារទឹក



សួតកើតជំងឺអាក់ទីណូបាក់ស៊ីលូស

## ១២ . ជំងឺអូហ្សេស្គី

ជំងឺនេះបង្កឡើងដោយវីរុស ហើយអាចបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់កូនជ្រូក ។

### ១២.១. រោគសញ្ញា

- កូនជ្រូកអាចស្លាប់ ១00% តែបើកើតឡើងចំពោះជ្រូកធំ អាចស្លាប់ ១-២ក្បាល
- កូនជ្រូកក្អួត រាគ ញាក់ញ័រ កន្ត្រាក់ខ្លួន ធាក់ជើងខ្វៃៗ
- ជួនកាលជ្រូកប្រកាច់ ដោយសារមេរោគវាយលុកលើប្រព័ន្ធប្រសាទ
- ហើម ឬគ្រាប់ភ្នែកលៀន រឹងថ្គាម
- មេផើម រលូតកូន



### ១២.២.ការព្យាបាល

ជំងឺនេះគ្មានថ្នាំព្យាបាលទេ តែអាចចាក់អង់ទីប៊ីយ៉ូទិកដូចជា អំពីស៊ីលីន អាម៉ុកស៊ីលីន ...ដើម្បីប្រឆាំងនឹងជំងឺឆ្លៀតឱកាសផ្សេងទៀត ។

### ១២.៣.ការការពារ

ចាក់ថ្នាំការពារឲ្យបានទៀងទាត់ តាមការណែនាំរបស់ក្រុមហ៊ុនផលិតថ្នាំ ។

## ១៣ . ជំងឺរាគ

ជំងឺរាគអាចបណ្ដាលមកពីទឹក ពីចំណី និងមេរោគ ។ ជាទូទៅទោះបីជាកូនជ្រូករាគ ក៏វានៅតែបន្តស៊ីចំណី គ្រាន់តែការលូតលាស់របស់វាយឺត ។

### ១៣.១. រាគបណ្ដាលមកពីទឹក

ទឹកអណ្ដូង ឬត្រពាំង ដែលនៅជិតទ្រុងជ្រូក តែងតែមានលាមកជ្រូកហូរ ឬជ្រាបចូល ជាហេតុធ្វើឲ្យទឹកនោះ ក្រខ្វក់ និងមានមេរោគ ។



លាមករាគមានសុទ្ធតែទឹក

ក. រោគសញ្ញា

កូនជ្រូករាគមានសុទ្ធតែទឹក និងលាមកមានពណ៌លឿង

ខ. ការព្យាបាល

ប្រើទ្រីមេតូព្រីម ជាមួយស៊ុលហ្វា

### ១៣.២. រាគបណ្តាលមកពីចំណី

វត្ថុធាតុដើមខ្លះមានគុណភាពអន់ ដូចជាពោត មានជាតិពុលមីកូតុកស៊ីន (ជ្រូកក្អួត) ម្សៅត្រីរក្សាទុកមិនបានល្អ ចំណីដែលមានតែកន្ទក់សុទ្ធ ឬកន្ទក់មានគុណភាពអន់ ធ្វើឲ្យជ្រូករាគមានសភាពផុកៗ ពណ៌ត្នោតស្រាល ។

**ការព្យាបាល**

ធ្វើការប្តូរចំណី ។



លាមករាគមានពណ៌ត្នោត

### ១៣.៣. រាគបណ្តាលមកពីមេរោគអ៊ីកូលី (E.Coli)

ជំងឺនេះបង្កឡើងដោយមេរោគអ៊ីកូលី (E.Coli) ។ ពេលផ្តាច់ដោះគឺជាពេលមួយដែលទឹកដោះចុះថយ និងអង់ទីគំររបស់កូនជ្រូកចុះខ្សោយ ជាឱកាសល្អដែលមេរោគអ៊ីកូលី បង្កបញ្ហាលើពោះវៀន បណ្តាលឲ្យកូនជ្រូក មានជំងឺរាគរ៉ាំរ៉ៃ ។

ប្រសិនបើពេលផ្តាច់ដោះកូនជ្រូកនៅក្មេងពេក ឬទម្ងន់តិចជាង ៦គក្រ ជាហេតុធ្វើឲ្យពួកវាងាយរាគ ។ ការរាគនេះកើតមានឡើងក្នុងកំឡុងពេល ៥ ថ្ងៃក្រោយពេលផ្តាច់ដោះ បង្កឲ្យកូនជ្រូកឈឺ និងស្លាប់ ។ កូនជ្រូក រាគ លាមកមានពណ៌ប្រផេះស លឿង និងបៃតង រាវ ឬម្សៅផុកៗ ។

គួរផ្តល់ចំណីផ្សំស្រេចដល់កូនជ្រូក ដែលមានជាតិប្រូតេអ៊ីន ២០% ព្រោះងាយស្រួលរំលាយ និងជួយឲ្យកូនជ្រូកលូតលាស់លឿន ។



កូនជ្រូករាគ លាមកមានពណ៌បៃតង




អង់រ៉ូហ្វុកសាក់ស៊ីន ៥% (Enrobioflox)

ការព្យាបាល

- ចាក់កូលីស្ទីន (Ampidexalone, Biocolistine, Ampicoli) ២សេសេ/ក្បាល ព្រឹក និងល្ងាច
- ឬចាក់អង់រ៉ូហ្លុកសាក់ស៊ីន ៥% (Enrobioflox) ២សេសេ/ ក្បាល/ថ្ងៃ
- លាយកូលីស្ទីន (Colistin) ក្នុងចំណីឲ្យកូនជ្រូកស៊ីរយៈពេល ៣ថ្ងៃ ។

១៣.៤. រាគបណ្តាលមកពីមេរោគកុកស៊ីឌីយ៉ូស៊ីស (Coc-cidiosis)

ជំងឺនេះកើតលើកូនជ្រូកអាយុពី ៧-២១ថ្ងៃ ។

ក. រោគសញ្ញា

- រាគប្រែពីពណ៌លឿង ទៅជាពណ៌ប្រផេះបៃតង។ កូនជ្រូកស្គមជ្រីវជ្រួញខុសពីធម្មតា ។

ខ. ការព្យាបាល

- ប្រើស៊ុលហ្វា (សិបទ្រីល សុលហ្វា ៣៣ ...)

គ. ការការពារ

- បញ្ជ្រកតុលត្រាសេរីល (បេកុក ឬ អង់ទីកុក) (Toltrazuril) ១មល តាមមាត់ ពេលកូនជ្រូកមានអាយុ ៣ថ្ងៃ ។



លាមកកូនជ្រូកមានជំងឺ Coccidiosis



កូនជ្រូកផ្តាច់ដោះបន្ទាប់ពីមានជំងឺ Coccidiosis

១៣.៥. រាគបណ្តាលមកពីមេរោគក្លូស្ទ្រីដ្យូម

ជំងឺនេះកើតឡើងចំពោះកូនជ្រូកដែលដើររកចំណីស៊ីដោយខ្លួនឯង ។

ក. រោគសញ្ញា

- កូនជ្រូករាគខ្លាំង មានក្លិនស្អុយ ជាទូទៅមានលាយឈាម
- កើតលើកូនជ្រូកអាយុពី១-៧ថ្ងៃ
- កូនជ្រូកស្លាប់ច្រើន

ខ. ការព្យាបាល

- ចាក់អាម៉ុកស៊ីលីន យកល្អគួរបញ្ជ្រកតាមមាត់។



កូនជ្រូកដើររកស៊ីចំណីដោយខ្លួនឯង



កូនជ្រូករាគបណ្តាលមកពីមេរោគ ក្លូស្ទ្រីដ្យូម

១៣.៦. រាគបណ្តាលមកពីជំងឺសាល់ម៉ូណែលឡ

ជំងឺនេះកើតឡើងលើជ្រូកក្នុងដំណាក់កាលកំពុងលូតលាស់ ។ ពេលដែលជ្រូកជាពីជំងឺប៉េស្ត ជាទូទៅវានឹងកើតជំងឺសាល់ម៉ូណែលឡាតាមក្រោយ ។

ក. រោគសញ្ញា

- រាគមានតែទឹក ក្លិនស្អុយ អាចមានលាយឈាម
- ឈឺចាប់ពេលដកដង្ហើម (ក្អក)
- ស្បែកខ្លួន និងស្បែកកន្ទុយមានពណ៌ក្រហមហើយ

ត្រចៀកមានពណ៌ខៀវ

- ខាន់លឿង ព្រោះថ្លើមខូច

ខ. ការព្យាបាល

- ចាក់អង់ទីប៊ីយ៉ូទិកសាក់ស៊ីន ។

គ. ការការពារ

- មិនត្រូវចាក់វ៉ាក់សាំងទេ
- ធ្វើអនាម័យទ្រុង ធ្វើការសម្លាប់មេរោគ និងកំចាត់កុំឲ្យមានសត្វកណ្ដុរ ។







លាមកមានតែទឹកលាយឈាម

១៣.៧. រាគបណ្ដាលមកពីរលាកពោះវៀន

ជំងឺនេះកើតឡើងចំពោះលើជ្រូកក្នុងដំណាក់កាលកំពុងលូតលាស់ ។

សភាពរ៉ាំរ៉ៃ: លាមករាគសុទ្ធតែទឹក មានពណ៌ ប្រផេះ ដែលធ្វើឲ្យការលូតលាស់យឺត

សភាពស្រួចស្រាវ : លាមករាគ មានលាយឈាម ធ្វើឲ្យជ្រូកមានសភាពស្លេកស្លាំង ។

ក. ការព្យាបាល

- ប្រើទីឡូស៊ីន (Tylosin) ដូចជាទីឡូប្លុក (Tylo+) និង ទីប៊ីយ៉ង់ (Tylbian) ... ។

រាគមានពណ៌ប្រផេះ

ខ. ការការពារ

- នៅពេលផ្លាស់ប្ដូរជ្រូកទៅទ្រុងបំប៉ន ត្រូវលាយទីឡូស៊ីន ជាមួយអុកស៊ីតេត្រាស៊ីគ្លីន (Tylosin + Oxytetracycline) ឲ្យវាស៊ីរយៈពេល ៥ថ្ងៃ
- ធ្វើអនាម័យទ្រុង ធ្វើការសម្លាប់មេរោគ និងកំចាត់កុំឲ្យមានសត្វកណ្ដុរ ។

**១៤. ព្រូនអាស្ការីស** (Ascaris)

អាស្ការីសមាននៅក្នុងពោះវៀន និងសួត ។ វាមានប្រវែងពី ២៥០-៤០០មម ។ មានព្រូនជាច្រើនរស់នៅក្នុងពោះវៀន បានស្រូបយកជីវជាតិ ដែលជ្រូកបានលេបចូល ធ្វើឲ្យជ្រូកមានការលូតលាស់យឺត ។ នៅពេលដែលកូនព្រូនធ្វើបន្លាស់ទីក្នុងសួត បណ្ដាលឲ្យជ្រូកក្អក ។

ការការពារ / ការព្យាបាល

- ចាក់អ៊ីវើមិចទីន (Ivermectine) ។



ព្រូននៅជាប់គូថជ្រូក

## ១៥. ក្លូន ឬអ៊ែរកនី

កើតឡើងដោយសារការដាច់សន្ទះផ្ចិត ឬក្រលៀន ដែលធ្វើឲ្យពោះវៀនធ្លាក់ទៅក្រោមស្បែក ធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់របស់សត្វ ។ ការធ្លាក់ពោះវៀននេះគ្មានការព្យាបាលទេ ។

### ១៥.១. រោគសញ្ញា

- ហើមទំហំពី ៣០-២០០មម លយចេញពីផ្ចិត និងពោះ ឬពីមុខពងស្វាស ។



ជ្រូកកើតក្លូន ដោយសារដាច់សន្ទះផ្ចិត

### ១៥.២. ការការពារ

- ចាក់អាម៉ុក អិលអេ លើកូនជ្រូកដែលទើបនឹងកើតបាន ២៤ម៉ោង ។
- មិនត្រូវក្រៀវកូនជ្រូកដែលធ្លាក់ពោះវៀនឡើយ ។

## ១៦. ជំងឺរលាកតម្រងនោម ឬផ្លោកនោម

ជំងឺនេះច្រើនកើតលើមេជ្រូក និងជ្រូកសាច់ ។ ប៉ុន្តែជ្រូកស៊ីចំណីជាធម្មតា ។

### ១៥.១. រោគសញ្ញា



ខ្ទុះលើកម្រាលឥដ្ឋ

- ជាជំងឺរ៉ាំរ៉ៃ តែមិនបណ្ដាលឲ្យជ្រូកស្លាប់ទេ
- ខ្ទុះលាយជាមួយទឹកនោម ឬមានទឹកហូរចេញពណ៌ស ជាប់ប្រដាប់បន្តពូជ
- មានខ្ទុះនៅលើកម្រាល ឬនៅជាប់ទ្រុង ។

### ១៥.២. ការព្យាបាល

- ប្រើអង់ទីប៊ីយ៉ូទិក ដូចជាចាក់ ឬលាយក្នុងចំណី នូវអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ឬ ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+sulfa) ។

### ១៥.៣. ការការពារ

- ផ្ដល់ទឹកស្អាត និងឲ្យជ្រូកផឹកទឹកឲ្យបានគ្រប់គ្រាន់។

## ១៧. ជំងឺរលាកស្បូន ឬផ្លោកនោម

មេជ្រូកមិនស៊ីចំណី ហើយបង្ហាញអាការៈឈឺចាប់ ។ ជំងឺនេះកើតមានឡើងក្រោយពេលមេជ្រូកកើតកូនបាន ៤-៥ថ្ងៃ

### ១៦.១. រោគសញ្ញា

- ភ្នែកក្រហម
- គ្រុនក្ដៅ សីតុណ្ហភាពលើស ៤០អង្សាសេ
- ទឹកពណ៌ស ឬពណ៌ត្នោត ហូរតាមប្រដាប់បន្តពូជ
- ជុំវិញប្រដាប់បន្តពូជមានភាពសើម ហើយហូរឈាម
- ទឹកនោមមានលាយឈាម និងខ្ទុះ
- អត់ទឹកដោះ
- មានសញ្ញាលៀសដោះ
- ជាទូទៅជ្រូកនឹងស្លាប់ក្នុងពេល ២-៣ថ្ងៃ ក្រោយ។



ឈាមហូរតាមប្រដាប់បន្តពូជ



ហូរខ្ទុះតាមប្រដាប់បន្តពូជ

### ១៦.២.ការព្យាបាល

- ចាក់អង់ទីប៊ីយ៉ូទិក ដូចជាអង់រ៉ូហ្វ្លុកសាក់ស៊ីន (Enrofloxacine) ២ដង/ថ្ងៃ
- ប្រើអង់ទីប៊ីយ៉ូទិកដូចជា អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ឬ ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+sulfa) ។

## ១៨. ដំបៅលើប្រដាប់បន្តពូជ

ពេលប្រដាប់បន្តពូជមានដំបៅ មេជ្រូកមិនអាចបង្កាត់បាន ព្រោះវាមានការលំបាកក្នុងការកើតកូន ហើយមេរោគក៏ងាយឆ្លងចូលក្នុងស្បូន ។ មូលហេតុបណ្តាលឲ្យមានដំបៅនៅប្រដាប់បន្តពូជ គឺមុតដោយសារខាំគ្នា ឬត្រដុសទ្រុង

### ១៨.១. រោគសញ្ញា

- មានស្នាមដាច់
- បូស ឬហើម ។

### ១៨.២. ការព្យាបាល

- យកមេជ្រូកឈឺចេញពីហ្វូង
- ប្រើអង់ទីប៊ីយ៉ូទិកដូចជា អាម៉ុកស៊ីលីន (Amoxi-cillin) ។

## ១៩. ទឹកនោមមានពណ៌ខុសពីធម្មតា

រាល់ពេលមេជ្រូកនោម ត្រូវពិនិត្យមើលទឹកនោមរបស់វា បើទឹកនោមប្រែពីពណ៌លឿងខ្ចីទៅជាពណ៌លឿងចាស់ បានន័យថា មេជ្រូកផឹកទឹកមិនគ្រប់គ្រាន់ ធ្វើឲ្យកំហាប់ទឹកនោមប្រែពណ៌ លាមកស្ងួត ភ្នែកខូង ។



ទឹកនោមមេជ្រូកមានពណ៌លឿងខ្ចី

### ១៩.១. ផលប៉ះពាល់

- ចំពោះមេបំបៅកូន ការផលិតទឹកដោះតិច
- ចំពោះមេដើម ធ្វើឲ្យរលាកផ្លោកនោម
- ចំពោះជ្រូកសាច់ ធ្វើឲ្យការលូតលាស់យឺត ដោយសារវាស៊ីចំណីតិច

### ១៩.២. ការព្យាបាល

- ចំពោះមេដើម ឲ្យវាផឹកទឹកពី ២០-៣០លីត្រ/ថ្ងៃ
- ចំពោះមេបំបៅកូន ឲ្យវាផឹកទឹកពី ៣៥-៤៥លីត្រ/ថ្ងៃ ។

## ២០. ដំបៅក្រពះ

មូលហេតុដែលធ្វើឲ្យក្រពះមានដំបៅ ដោយសារគុណភាពវត្ថុធាតុដើមក្នុងចំណីអន់ និងក្នុងចំណីមានជាតិសរសៃមិនគ្រប់គ្រាន់ ។



ក្រពះមានដំបៅ

២០.១. រោគសញ្ញា

- ជាទូទៅកើតលើមេជ្រូក និងជ្រូកសាច់
- មិនស៊ីចំណី តែសីតុណ្ហភាពក្នុងខ្លួនឡើង
- ស្បែកស្លេកស្លាំង (ដោយសារហូរឈាម)
- លាមកក្តៀន (លាមកពណ៌ខ្មៅ)
- ក្អួត

២០.២. ការព្យាបាល

- ផ្តល់ចំណី ៤-៥ដង/ថ្ងៃ ដោយលាយជាមួយទឹកដើម្បីឲ្យចំណីទន់
- ផ្តល់បន្លែស្រស់
- ចាក់ការ៉ាស៊ីល (Carasil) អេម៉ាតូប៉ង់ (Hematopan) ដើម្បីជំរុញឲ្យវាស៊ីចំណី
- ផ្តល់វីតាមីនបេ១២ (Vitamin $B_{12}$) ។

## ២១. ការប្រកាច់

ការប្រកាច់បង្កឡើងដោយមេរោគ ស្រ្តិបតូកុកគូស (Streptococcus) ។ ជំងឺនេះច្រើនកើតលើកូនជ្រូកផ្តាច់ដោះ ។ ជួនកាលមានកូនជ្រូកស្លាប់ ១-២ ក្បាល ដោយមិនបញ្ចេញរោគសញ្ញា ។ ចំណែកកូនជ្រូកដែលឈឺ ឬស្លាប់ ច្រើនតែកូនជ្រូកដែលធំជាងគេ ។



*កូនជ្រូកប្រកាច់*

២១.១. រោគសញ្ញា

- ដើរទ្រេតទ្រោត រួចប្រកាច់ជើងខ្វៃៗ
- កូនជ្រូកដេកផ្អៀង ហើយញាក់ៗ បែកពពុះមាត់
- លាមកក្តៀន (លាមកពណ៌ខ្មៅ
- មានសីតុណ្ហភាព ៤១អង្សាសេ
- កូនជ្រូកអាចនិងស្លាប់នៅ ២-៣ម៉ោងក្រោយ

២១.២. ការព្យាបាល

- យកកូនជ្រូកដែលឈឺចេញ និងដាក់វានៅកន្លែងស្ងាត់
- ដំបូងចាក់ដិចហ្សាមេតាហ្សូន (Dexamethasone) ឬតុលហ្វេឌីន (Tolfedine)
- បន្ទាប់មកចាក់អាម៉ុកស៊ីលីន (Amoxicillin)
- ផ្តល់វីតាមីនបេ១២ (Vitamin $B_{12}$) ។

២១.៣. ការការពារ

- មុននឹងយកកូនជ្រូកទៅដាក់នៅទ្រុងផ្តាច់ដោះ ត្រូវធ្វើការសម្លាប់មេរោគក្នុងទ្រុងជាមុនសិន ។
- នៅពេលមានកូនជ្រូកណាមួយឈឺ ចាំបាច់ត្រូវលាយអាម៉ុកស៊ីលីន (Amoxicillin) ក្នុងចំណីឲ្យកូនជ្រូកទាំងអស់ក្នុងទ្រុងស៊ី រយៈពេល ៥ថ្ងៃជាប់គ្នា ។

## ២២. ជំងឺតេតាណូស

ជំងឺតេតាណូស បណ្តាលមកពីមិនបានធ្វើអនាម័យល្អនៅពេលក្រៀវ ឬពេលកាត់ទងផ្ចិត ។



*រោគសញ្ញានៃជំងឺតេតាណូស*

២២.១. រោគសញ្ញា

- រឹងជើង និងសាច់ដុំ
- កន្ទុយត្រង់

២២.២. ការព្យាបាល

- ដំណាក់កាលដំបូងប្រើប៉េនីស៊ីលីនកម្រិតខ្ពស់ប្រចាំថ្ងៃ (កម្រិតទ្វេដង) ។

## ២៣. ជំងឺហើម

កើតឡើងដោយសារការផ្តាច់ដោះ និងការផ្លាស់ប្តូរចំណី ជំងឺនេះបង្កឡើងដោយបាក់តេរី (E.Coli) ដែលធ្វើឲ្យ

បែកសរសៃឈាម ជាពិសេសសរសៃឈាមខួរក្បាល (រោគសញ្ញាប្រព័ន្ធប្រសាទលេចចេញឡើង) ។



ជាំឈាមនៅបរិវេណភ្នែក

២៣.១. រោគសញ្ញា

- កើតឡើង ២សប្តាហ៍ ក្រោយពេលផ្តាច់ដោះ
- ជ្រូកមិនអាចបញ្ជាខ្លួនឯងបាន ដើរដូចមនុស្សស្រវឹង
- ភ្នែកក្រហម (រលាកជុំវិញបរិវេណភ្នែក) ដោយមានហូរទឹកមកជាមួយ មិនយូរប៉ុន្មានត្របកភ្នែកនឹងបិទជិត ហើយស្អិត
- មានសីតុណ្ហភាពលើស ៤១អង្សាសេ
- ជាំឈាមក្រោមស្បែក
- កូនជ្រូកស្លាប់លឿន ដោយមិនទាន់បានព្យាបាល

២៣.២. ការព្យាបាល

- យកកូនជ្រូកដែលឈឺចេញ និងដាក់វានៅកន្លែងស្ងាត់
- ចាក់ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+sulfa) ឬអង់រ៉ូហ្វ្លកសាក់ស៊ីន (Enrofloxacine) ។

២៣.៣. ការការពារ



នៅពេលប្រឹងដើរ ជ្រូកមិនអាចបញ្ជាខ្លួនឯងបាន

- ផ្តល់ចំណីពិសេសដល់កូនជ្រូកផ្តាច់ដោះ
- ប្រើក្លរីនសម្លាប់មេរោគអីកូលី (E.Coli) ក្នុងទឹក

## ២៤. ជំងឺរលាកសន្លាក់

ជំងឺនេះបង្កឡើងដោយសារបាក់តេរី ស្រ្តិបតូកុកកូស (Streptococcus) ដែលតែងកើតលើកូនជ្រូកកំពុងបៅដោះ។

២៤.១. រោគសញ្ញា

- ខ្វកជើង ហើមសន្លាក់
- ជ្រូកមានសភាពឈឺចាប់
- មិនចង់ក្រោកឈរ



កូនជ្រូកមានបញ្ហារលាកសន្ទាក់

២៤.២. ការព្យាបាល

- ប្រើឡាំងកូមីស៊ីន (Lincomycin) អាម៉ុកស៊ីលីន Amoxicillin) ។

២៤.៣. ការការពារ

- ត្រូវចាក់អាម៉ុកស៊ីលីន អិលអេ (Amoxicillin LA) ក្រោយពេលកូនជ្រូកកើតបាន ១ថ្ងៃ ។

## ២៥. បែកក្រចកជើង

ការបែកក្រចកជើងច្រើនមាននៅចន្លោះខ្នែងក្រចក និងក្រចកជើង ដោយសារកម្រាលមិនល្អ ។

២៥.១. រោគសញ្ញា

- ជ្រូកពិបាកដើរ ព្រោះហើមកជើង
- សភាពហើម មាននៅជុំវិញកជើង ហើយបង្កជារបួស

២៥.២. ការព្យាបាល

- ប្រើឡាំងកូមីស៊ីន (Lincomycin) / ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា (TMP+sulfa)

- កម្រាលទ្រុងត្រូវរាយអង្កាមពីលើ
- បាញ់ស្ព្រាយពពួកអុកស៊ីតេត្រាស៊ីគ្លីន (Spray OTC) ត្រង់មុខរបួស ។



ស្នាមដំបៅនៅជើង



ព្យាបាលដោយប្រើ អុកស៊ីតេត្រាស៊ីគ្លីន (Spray OTC)

## ២៦. ជំងឺអុតក្តាម (FMD)

### ២៦.១. រោគសញ្ញា

- ក្រចកជើងលឿន
- ជ្រូកចូលចិត្តដេក
- នៅពេលដើរ ជ្រូកមានសភាពឈឺចាប់ ហើយស្រែកខ្លាំង
- មានពងដោរនៅគល់ក្រចក និងច្រមុះ។

### ២៦.២. ការព្យាបាល

- ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+sulfa) អុកស៊ីតេត្រាស៊ីគ្លីន (OTC)
- សំអាតមុខរបួសជាមួយសាប៊ូ ហើយបាញ់ស្ព្រេពពួកអុកស៊ីតេត្រាស៊ីគ្លីន (Spray OTC)
- ប្រើអាណាហ្សាំង (Analgine) តុលហ្វេឌីន (Tolfedine) ដើម្បីបញ្ចុះកំដៅ ។

### ២៦.៣. ការការពារ

- ចាក់វ៉ាក់សាំងការពារជំងឺអុតក្តាម ។

